01502122

E1/303.1/Corr-3

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

## សំណើសុំការកែតម្រូវ

| ឯកសារដើម |
| --- |
| ORIGINAL/ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2017, 14:50 |
| CMS/CFO: Sann Rada |

**សំណុំរឿងលេខ: 002/19-09-2007-ECCC/TC**

| កែលើឯកសារលេខ: | ERN(s): | កាលបរិច្ឆេទ: | ប្រភេទកំណែ: |
| --- | --- | --- | --- |
| E1/303.1 | 01101551 - 01101596 | 15 June 2017 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំទាត់ថ្នាក់ឡើងវិញ |

**មូលហេតុនៃការកែតម្រូវ**

កំណែប្រែដូចបង្ហាញក្នុងប្រតិចារឹកនេះគឺជាលទ្ធផលនៃការត្រួតពិនិត្យប្រកបដោយគុណភាព ដែលធ្វើឡើងដោយអង្គភាពប្រតិចារឹក ដោយមានការចង្អុលបង្ហាញពីការិយាល័យរដ្ឋបាល ហើយដែលបានជូនដំណឹងដល់ភាគីកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។ កំណែប្រែនេះបង្ហាញប្រាប់អំពីចំណុចខ្វះខាតលើខ្លឹមសារ ឬភាពមិនត្រឹមត្រូវ ដែលត្រូវបានកែសម្រួល ដោយធ្វើការប្រៀបធៀបទៅនឹងភាសាដើមដែលភាគីបានថ្លែងនៅក្នុងសវនាការ និងអ្វីដែលត្រូវបានបកប្រែដោយអ្នកបកប្រែ។

**សេចក្ដីលម្អិតនៃការកែតម្រូវ**

ការកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ទប់បកប្រែ និងខ្ទប់បកប្រែបន្ត។

ភាគីស្នើសុំ: អង្គភាពប្រតិចារឹក ហត្ថលេខា

បានទទួលការឯកភាពពីក្រឡាបញ្ជី (ចំពោះឯកសារដើម): ហត្ថលេខា

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា (ចំពោះការបកប្រែ): ហត្ថលេខា

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៨នាទី**

**សវនាការលើកទី២៨៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ារី-ជេនី សាដាទិ
*(Ms. Marie-Jeannes SARDACHTI)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
(*Mr. Vincent de wilde d'ESTMAEL)*

*លោក ស្រ៊ា រតនៈ*

*លោក ត្រាវិស ហ្វារ* (Mr.Travis FARR)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms.Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្ង សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ប៉ិច សុខា (2-TCW-909) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ប៊ិច សុខា** (2-TCW-909)

សួរបន្តដោយលោក ត្រាវិស ហ្វារ ផ្ដើមពី ....................................................................ទំព័រ ៤
សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី ....................................................................ទំព័រ ១១
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ....................................................................ទំព័រ ២០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................................................................ទំព័រ ២៨
សួរដោយលោក អង់តា ហ្គីសសេ ផ្ដើមពី....................................................................ទំព័រ ៣៧
សួរដោយលោក គង់ សំអុន ផ្ដើមពី ....................................................................ទំព័រ ៤១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៧:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ប៊ិច សុខា តាមរយៈប្រព័ន្ធសោតទស្សន៍។

កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ប៊ិច សុខា តាមរយៈប្រព័ន្ធសោតទស្សន៍។ តាមការបញ្ជាក់ ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការផ្តល់សក្ខីកម្ម នៅពេលនេះ បានរៀបចំរួចរាល់ហើយ រីឯសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្ម នេះផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៩:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ជា ស៊ីវហ័ង។

ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនចាប់ចោទ នួន ជា ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាព ចូលរួម

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ ផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថាការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការណ៍ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា មានអាការៈនៅដដែលគឺមានអាការៈវិលមុខ និងឈឺចង្កេះមិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:១០:៤៨]

ផ្អែកលើមូលដ្ឋាននេះ និងយោងទៅតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

អង្គជំនុំជម្រះសួរទៅខាងតំណាងសហព្រះរាជអាជ្ញា តើនៅមានសំណើសុំដដែលទេ? ឬក៏មានការផ្លាស់ប្ដូរជំហរឡើងវិញក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត យើងនៅសល់មួយផ្នែកទៀតដែលយើងត្រូវសាកសួរសាក្សីរូបនេះ។ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាត ប៉ុន្តែទី១គឺ គប្បីតាំងសំណួរឲ្យចូលទៅជាប្រភេទ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សំណួរសារធាតុដែលពាក់ព័ន្ធជាមួយអង្គហេតុចោទប្រកាន់។ បញ្ហាទី២គឺ អង្គជំនុំជម្រះផ្ដល់ពេលវេលារួមជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយវគ្គនៃសវនាការនេះតែបណ្ដោះ។

បាទ សូមអញ្ជើញ!

[០៩:១២:៤៥]

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន <ខ្ញុំយល់ពី>ការសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញគឺ ខាងព្រះរាជអាជ្ញា និងខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីគឺមានពេលបីពេល។ ដូច្នេះ តើខ្ញុំយល់បែបនេះជាការត្រឹមត្រូវដែរឬទេអំពីការសម្រេចរបស់អង្គជំនុំជម្រះ?

Deleted: តាម

**ប្រធានអង្គជំនុំ៖**

បាទ ជាការត្រឹមត្រូវហើយ ប៉ុន្តែសហព្រះរាជអាជ្ញាបានបញ្ចប់នូវសំណួររបស់ខ្លួនរួចហើយកាលពីម្សិលមិញ ដោយសុំសួរបីសំណួរទៀតចំណាយពេលវេលាប្រាំនាទីក្នុងការសួរបញ្ចប់។ អង្គជំនុំជម្រះបានយល់ព្រមរួចហើយ។ អ៊ីចឹង គឺយើងបានទទួលដំណឹងតាមអ៊ីម៉ែលក្រោយពេលបញ្ចប់ការសវនាការទេ ដែលយើងសួរបញ្ជាក់នេះ ដើម្បីផ្ដល់លទ្ធភាពឲ្យលោកអាចមានឱកាសបន្តការតាំងសំណួរ ប៉ុន្តែនៅក្នុងក្របខ័ណ្ឌមួយគឺគោលបំណងដើម្បីបញ្ចប់សវនាការសួរសក្ខីកម្ម -- ស្ដាប់សក្ខីកម្មសាក្សីរូបនេះ នៅក្នុងថ្ងៃនេះ។ មូលហេតុមួយគឺ សាក្សីរូបនេះមានបញ្ហាសុខភាពផង ហើយបញ្ហាទី២គឺ បើសិនជាយើងបន្តដំណើរការទៅសវនាការបន្តនៅថ្ងៃស្អែក នោះគឺយើងនឹង -- បើសិនជាមិនចប់ទេ យើងមិនអាចធ្វើនៅសប្ដាហ៍ក្រោយបានទេ គឺយើងត្រូវធ្វើនៅថ្ងៃស្អែក។ នេះជាមូលហេតុដែលយើងកំណត់ដូច្នេះ។

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ខ្ញុំសុំអនុញ្ញាតជជែកជាមួយខាងដើមបណ្ដឹងរដ្ឋប្បវេណីបន្តិចទាក់ទងនឹងការបែងចែកពេលវេលា។

[០៩:១៤:២៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសុំការបំភ្លឺពីអង្គជំនុំជម្រះ គឺថាយើង និងសហព្រះរាជអាជ្ញាគឺមានពេល១ម៉ោងសម្រាប់សួរ។ អ៊ីចឹងយើងគិតថា ពេលព្រឹកនេះ គឺថាយើងបែងចែកពេលគ្នាដើម្បីឲ្យសហព្រះរាជអាជ្ញាគាត់អាចសួរសំណួរបន្ថែមដែលខ្លួនចង់សួរ ហើយដូចដែលឯកភាពគ្នាអ៊ីចឹងគឺថា គឺយើងចង់បានពេលវេលាដែល

Deleted: យើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងគ្រោងទុក នៅពេលដែលយើងនិយាយអំពីការបែងចែកពេលវេលាសម្រាប់សាក្សីរូបនេះ។ អ៊ីចឹងបើយើងគិតសរុបទាំងអស់ទៅគឺថា យើងត្រូវការពេលទាំងពីរក្រុមយើងគឺថា ១ម៉ោង ២០នាទី នេះជាពេលវេលាប្រហាក់ប្រហែលទេ។ អ៊ីចឹងប្រហែលជា<យើងខ្ញុំ>អាចប្រើពេលតិចជាងហ្នឹងផង បើតាមជាក់ស្ដែងទៅ។ ក៏ប៉ុន្តែបើៗយើងគិតទៅគឺ ១ម៉ោង និង២០នាទីដើម្បីអាចឲ្យសហព្រះរាជអាជ្ញាក៏គាត់អាចសួរសំណួររបស់គាត់បានដែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ដូចមិនខុសអីផង បើសិនជាសួរទៅបានប្រហែល១០នាទីនេះ ព្រោះពេលព្រឹកនេះ វាបាន១ម៉ោង ១០នាទីទៅហើយ។ អញ្ជើញ ត្រឹម១ម៉ោង ២០នាទី យើង និងអង្គជំនុំជម្រះនឹងបន្ថែមឲ្យ១០នាទីថែមទៀត។

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។

តើខ្ញុំអាចចាប់ផ្ដើមសួរសំណួរសាក្សីបានឬទេ? តើវីឌីអូលីង ដំណើរការហើយឬនៅ?

**ប្រធានអង្គជំនុំ៖**

សួរស្ដីលោក ប៊ិច សុខា តើលោកបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក ប៊ិច សុខា៖**

ជម្រាបសួរលោកប្រធាន បានអង្គុយរង់ចាំរួចស្រេចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ប៊ិច សុខា។ ឥឡូវនេះយើងបន្តការតាំងសំណួរដេញដោលចំពោះលោកតទៅទៀត ដែលនៅចាប់ផ្ដើមដំបូងនេះដោយសហព្រះរាជអាជ្ញា។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:១៦:៥៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ត្រាវិស ហ្វារ៖**

**ស៖** សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក ប៊ិច សុខា។ នៅព្រឹកនេះ ខ្ញុំសូមចាប់ផ្ដើមសួរអំពីសម្រង់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺខ្មែរមានលេខ 00389528, ភាសា

អង់គ្លេសមានលេខ 00403009 និងភាសាបារាំងមានលេខ 00422244។ នៅទំព័រនេះគេសួរលោកដូចតទៅនេះ៖ “តើលោកដឹងអំពីការបោសសម្អាតមេដឹកនាំភូមិភាគកណ្ដាលដែរឬទេ?” លោកឆ្លើយថា “ខ្ញុំមិនដឹងទេ ប៉ុន្តែនៅពេលដែលខ្ញុំទៅជួបប្អូនប្រុសរបស់ខ្ញុំ <ដែលស្នាក់នៅជាមួយ>ឈ្មោះ ស្រេង នៅឯមន្ទីរសាធារណការតំបន់៤១ ទើបដឹងថា ស្រេង បានបាត់ខ្លួន<ទៅហើយ>។ ពេលនោះ តាំង បានឡើងជំនួស។ ក្រោយមកទៀត ពេលខ្ញុំទៅលេងប្អូនខ្ញុំជាលើកទី២ តាំង ក៏បានបាត់ខ្លួនទៀត។ ស្រេង និង តាំង ជាមិត្តភក្តិរបស់ឪពុកខ្ញុំ គាត់ទាំងពីរនាក់បានបាត់ខ្លួននៅឆ្នាំ១៩៧៧។”បញ្ចប់ការដកស្រង់។ ហើយនៅក្នុងចម្លើយលោកកន្លងមកកាលពីម្សិលមិញ លោកបានប្រាប់យើងថា ស្រេង គឺជាគណៈតំបន់៤១ ហើយ ស្រេង គឺជាអ្នកចាត់តាំងលោកឱ្យមករៀននៅភ្នំពេញ <នោះជាចម្លើយរបស់លោកជាភាសាខ្មែរដែល>មានលេខ 00389520 ដល់21, អង់គ្លេសមានលេខ 00403002 ដល់ 03 និងបារាំងមានលេខ 00422237។ ដូច្នេះ ខ្ញុំចង់សួរលោកអំពីការដែលលោកទៅជួបប្អូនប្រុសរបស់លោក<លើកដំបូងនៅឯមន្ទីរសាធារណការ>តំបន់៤១ ខ្ញុំចង់ដឹងថាតើលោកទៅជួបប្អូនលោកនៅតំបន់៤១ហ្នឹង នៅពេលណាដែរ?

Deleted:

Deleted: ។ គឺឯកសាររបស់លោក

[០៩:១៩:១៣]

**លោក ប៊ិច សុខា៖**

**ផ៖** សូមជម្រាបលោកតុលាការ ទាក់ទងនឹងរបាយការណ៍អំមិញនេះ ហ្នឹងជាសម្ដីរបស់ខ្ញុំនិយាយពិតហើយ។ ដូច្នេះអ្វីដែលខ្ញុំនិយាយក្នុងហ្នឹង ខ្ញុំដឹងត្រឹមប៉ុណ្ណឹង ឯរយៈដែលខ្ញុំទៅលេងប្អូនខ្ញុំនៅឆ្នាំ១៩៧៨ បាទ មានប៉ុណ្ណឹង។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើពេលដែលលោកទៅលេងប្អូនហ្នឹង គឺនៅក្រោយពេលដែលលោកទៅដល់ទំនប់១មករា ប្រហែលជាប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ?

**ផ៖** ខ្ញុំទៅលេងប្អូនខ្ញុំប្រហែលជារយៈពេល ចន្លោះប្រហែលជាមួយឆ្នាំៗជាងបន្តិច ប៉ុណ្ណឹងទេ។ បើឱ្យច្បាស់វាមិនច្បាស់ ប៉ុនគ្រាន់ការស្មាន ថាប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកទៅលេងប្អូនរបស់លោកហ្នឹង លោកធ្វើយ៉ាងណាបានដឹងថា ស្រេង គាត់លែងនៅមន្ទីរសាធារណការតទៅទៀតនោះ?

**ផ៖** ស្រេង មិនមែននៅមន្ទីរសាធារណការទេ ស្រេង ជាគណៈតំបន់៤១ បាទ។

**ស៖** ដូច្នេះ នៅពេលដែលលោកទៅលេងប្អូនលោកហ្នឹង តើលោកដឹងថា គាត់បាត់ខ្លួនហ្នឹង ដឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដោយរបៀបណា? អ្នកណាជាអ្នកប្រាប់លោក? ហើយលោកដឹងព័ត៌មានហ្នឹងពីអ្នកណាដែរ?

**ឆ៖** ដឹងតាមរយៈប្អូនខ្ញុំ ព្រោះប្អូនខ្ញុំប្រាប់ថា ខ្ញុំសួររកថា “ស្រេង ទៅណា?” គេថា “បាត់ហើយ” តែមិនដឹងថាបាត់ហ្នឹងទៅណាយើងក៏មិនដឹងដែរ។

**សៈ** <និយាយពី តាំង វិញម្ដង។ លោកថា គាត់ត្រូវបានជំនួសដោយ តាំង។ តើលោកអាចប្រាប់បានទេថា តាំង ជានរណា? ហើយគាត់មានតួនាទីអ្វីដែរ?>

Deleted: *(គ្មានការបកប្រែ)*

[០៩:២១:៥០]

*(មានបញ្ហាបច្ចេកទេស)*

[០៩:២៤:១៥]

**ប្រធានអង្គជំនុំ៖**

សួស្ដី លោក ប៉ិច សុខា!

**លោក ប៉ិច សុខា៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អំមិញមានបញ្ហាបច្ចេកទេស វាមានការរអាក់រអួលដោយសារបច្ចេកទេសខាងប្រព័ន្ធសោតទស្សន៍ ក្នុងការបកប្រែភាសាមានបញ្ហា។ ឥឡូវយើងបន្តកិច្ចដំណើរការយើងបន្តទៀតណា លោក ប៉ិច សុខា ចាំស្ដាប់សំណួរ។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**សៈ** លោក សុខា នៅក្នុងចម្លើយរបស់លោកៗបាននិយាយថា តាំង ឡើងជំនួស ស្រេង។ អ៊ីចឹងបានន័យថា តាំង គាត់ឡើងធ្វើលេខាតំបន់<បន្ទាប់ពី> ស្រេង អ៊ីចឹងមែនទេ?

Deleted: ជំនួស

**លោក ប៉ិច សុខា៖**

**ឆ៖** បាទ ការពិតគឺក្រោយពីបាត់ ស្រេង ទៅ តាំង ឡើងបន្ត។

**សៈ** តើលោកអាចប្រាប់បានទេថា លោកដឹងថា តាំង បាត់ខ្លួនហ្នឹងដឹងដោយរបៀបណាដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** រយៈពេលហ្នឹងគឺនៅចុងក្រោយហើយ ជិតៗដាច់ឆ្នាំ៧៨ហើយបានខ្ញុំដឹង ខ្ញុំទៅលេងប្អូនខ្ញុំម្តងទៀត ជាលើកចុងក្រោយមុននឹងខ្ញុំបែកពីប្អូនខ្ញុំ គឺដឹងត្រឹមតែប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកឡើងមកជំនួស តាំង ធ្វើជាលេខាតំបន់ទៀត?

**ឆ៖** ខ្ញុំលែងបានព័ត៌មានអ្វីទាំងអស់ គឺចប់ត្រឹមប៉ុណ្ណឹង។

[០៩:២៦:២០]

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាននៅក្នុងបរិបទនៃភស្តុតាងនេះ<ចេញពីសាក្សី>គឺថា ខ្ញុំចង់បញ្ជាក់ជាកំណត់ត្រាឯកសារពីរបី។ <ខ្ញុំនឹងមិនប្រើឯកសារនេះជាមួយនឹងសាក្សីនោះទេ តែ>ខ្ញុំចង់ឱ្យអង្គជំនុំជម្រះចាប់អារម្មណ៍បន្ថែមទៀតទៅលើឯកសារនោះ។ ឯកសារទី១ គឺE3/ -- គឺឯកសារ E3/2956 ជាបញ្ជីឈ្មោះអ្នកទោសនៅស-២១ ហើយបុគ្គលទី១ <ក្នុងបញ្ជីនោះមាន>ឈ្មោះ ស្រេង ដែលបញ្ជាក់ថាជាគណៈអចិន្ត្រៃយ៍របស់<ភូមិភាគឧត្តរ>។ ហើយនៅក្នុងលេខ<៥៦ ក្នុងបញ្ជីដដែល> គឺបុគ្គលម្នាក់មានឈ្មោះថា តាំង គឺជាលេខាតំបន់<>៣១ ប៉ុន្តែដោយសារខ្ញុំគិតថានេះគឺជាកំហុសវាយខុសពី៤១ ទៅ ៣១ទេ។

<យើងសូមឱ្យអង្គជំនុំជម្រះចាប់អារម្មណ៍ផងដែរចំពោះ>ឯកសារមួយទៀត E3/3857 និង E3/2797 គឺជាចម្លើយសារភាពនៅស-២១ របស់ឈ្មោះ ស្រេង និង E3/2464 គឺជាចម្លើយសារភាពរបស់ឈ្មោះ តាំង។ ដូច្នេះខ្ញុំគិតថា ដោយផ្អែកទៅលើឯកសារទាំងអស់នេះគឺយើងអាចកំណត់ថា បុគ្គលទាំងអស់នេះស្ថិតនៅស-២១។ ហើយ តាំង ក៏មាននៅក្នុង -- គឺមាននៅក្នុងឯកសារ E3/3861 <ជាបញ្ជីអ្នកទោសពីភូមិភាគឧត្តរ>ដែលត្រូវបានសម្លាប់នៅក្នុង<ថ្ងៃទី៨> ខែកក្កដា ឆ្នាំ<៧៧> ហើយមានឈ្មោះ តាំង នៅក្នុងនោះផងដែរ<គឺលេខរៀងទី១០៣>។

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីសួរនូវសំណួរពីរបីបន្ថែមទៀត ដែលគាត់និយាយអំពីអតីតមេរបស់គាត់ឈ្មោះ អៀង ឆាំ។ ហើយសំណួរនេះគឺពាក់ព័ន្ធទៅនឹងបញ្ហាដែលថាកំណត់ហេតុរបស់លោក ឆាំ គឺពាក់ព័ន្ធទៅនឹងការងារពីរដែលក្រុមគាត់បានធ្វើ ហើយសាក្សីនោះក៏គាត់អាចពឹងផ្អែកទៅលើកំណត់ហេតុនេះ ដឹងអំពីអ្វីដែលគាត់អាចប្រាប់បាន។ សូមអង្គជំនុំជម្រះអនុញ្ញាត។

[០៩:២៨:២៧]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោក សុខា ឥឡូវនេះ ខ្ញុំនឹងធ្វើការអាននូវកំណត់ហេតុស្តាប់ចម្លើយមិនមែនចម្លើយរបស់

Deleted: តំបន់

Deleted: ១៦

Deleted: ៤១ ហើយគឺ

Deleted: ៧៨

Deleted: ដែលថា លោក --

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកទេ ប៉ុន្តែជាចម្លើយរបស់ អៀង ឆាំ ដែលជាអតីតមេរបស់លោក។ ឯកសារគឺ E3/5513 លោក សុខា ខ្ញុំជឿជាក់ថា បុគ្គលិកតុលាការនៅជាមួយលោក ហើយប្រហែលជាមានឯកសារនេះជូនលោក ពិនិត្យមើលហើយ។ ដូច្នេះ សំណួរទី១ ដែលខ្ញុំចង់អានគឺសំណួរចម្លើយ៥៣<។ ត្រង់នោះ លោក> ឆាំ បាននិយាយថា ខ្ញុំសូមដកស្រង់៖ “ដំបូង សោ និង ខ្ញុំទទួលបានបញ្ជាពី កែ ពក ដើម្បីទៅមើលទីតាំង និងវាស់វែងទំនប់១មករា ក្នុងតំបន់៤២ ស្រុកបារាយណ៍។ <មេ>ក្រុមឈ្មោះ សោ ប្រពន្ធឈ្មោះ ស៊ីម (មិនដឹងស្លាប់ឬរស់) មកពីក្រសួងសាធារណការ<>”។ សូមបញ្ចប់ការដកស្រង់។

[០៩:២៩:៣៤]

ឥឡូវនេះ ខ្ញុំសូមបន្តទៅសំណួរ៥៨ គេបានសួរ ឆាំ ដូចតទៅនេះ៖ “នៅពេលដែលលោកធ្វើការ វាស់វែងនោះ តើលោករាយការណ៍ទៅអ្នកណា?” ហើយគាត់បានឆ្លើយថា៖ “ខ្ញុំរាយការណ៍ទៅឱ្យឈ្មោះ សោ”។ ហើយ<រំលង>ទៅសំណួរចម្លើយ៨៣ ខ្ញុំសូមដកស្រង់៖ “ពេលនោះ ក្រុមរបស់ខ្ញុំមានការប្រឹង ប្រែងធ្វើការងារយ៉ាងខ្លាំង ធ្វើយ៉ាងណាឱ្យបានទាន់តាមការកំណត់របស់ថ្នាក់លើ។ បើកាលណាយើង មិនអាចធ្វើរួចរាល់តាមផែនការគេកំណត់ទេ យើងនឹងមានគ្រោះថ្នាក់ដល់ខ្លួនជាមិនខាន។ ឧទាហរណ៍ ដូចជា ផ្នែកខាងមុខឈ្មៀងទំនប់ដែល សោ បានបញ្ជាថា ឱ្យយើងប្រើស៊ីម៉ង់ត៍ និងដែកតិច មានន័យថា ត្រូវប្រើសម្ភារៈដោយសំចៃអស់តិច និងឱ្យមានគុណភាព។ ប៉ុន្តែក្រោយពីសាកល្បងបើកទ្វារទឹកផ្នែក ខាងក្រោយ ពេលនោះ មុខឈ្មៀងក៏ត្រូវបានបាក់អស់ពាក់កណ្តាល។ បានធ្វើឱ្យក្រុមខ្ញុំមានការភ័យខ្លាច យ៉ាងខ្លាំង ព្រោះអាចត្រូវគេចោទថា យើងប្រើខុសបច្ចេកទេស”។ សូមបញ្ចប់ការដកស្រង់។ ហើយនៅ សំណួរបន្ទាប់ នៅខាងក្រោមជាប់គ្នានោះគឺថា “តើ សោ បាត់ខ្លួននៅពេលណា?” ហើយ ឆាំ បានឆ្លើយ ថា “ខ្ញុំមិនដឹងទេ។ គ្រាន់តែខ្ញុំមិនឃើញគាត់មកពិនិត្យមើលការដ្ឋានដូចមុនទៀត ក្រោយពីមានបញ្ហា មក”។ ហើយចុងក្រោយនៅសំណួរចម្លើយ៨៥ ឆាំ បានឆ្លើយថា “ក្រោយពីការបាត់ខ្លួន សោ, កែ ពក បានតែងតាំងខ្ញុំឱ្យទទួលបន្ទុកធ្វើការសាងសង់បន្ត”។ លោក សុខា ចម្លើយរបស់អតីតមេរបស់លោកធ្វើ ឱ្យលោកនឹកឃើញអំពីឈ្មោះ សោ ដែលបានបាត់ខ្លួនក្រោយពេលដែលបាក់មុខឈ្មៀងហ្នឹងដែរឬទេ?

[០៩:៣១:៤៣]

**លោក ប៉ិច សុខា៖**

**ឆ៖** ជម្រាបសួរលោកតុលាការ មកដល់ពេលនេះ ខ្ញុំពិតដូចជាមិនដែលឮឈ្មោះ សោ នោះផង សម្រាប់ខ្ញុំ។ ខ្ញុំស្គាល់តែឈ្មោះ ឆាំ ហ្នឹងទេ។

Deleted:
Deleted: អ្នកដឹកនាំ
Deleted: ចំណែកខ្ញុំជាអ្នកបច្ចេកទេស
Deleted: លោក --
Deleted:

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** កាលពីម្សិលមិញ លោកនិយាយថា លោកមានអារម្មណ៍ភ័យខ្លាចរន្ធត់<ចំពោះអ្វីដែលលោកធ្លាប់ឆ្លងកាត់>។ តើមូលហេតុអ្វីទើបលោកភ័យរន្ធត់? ហេតុអ្វីបានជាលោកភ័យថា ប្រសិនបើលោកធ្វើកំហុស ឬក៏មានកំហុស លោកអាចនឹងបាត់ខ្លួន? លោកអាចពន្យល់បានទេ?

**ឆ៖** ខ្ញុំអត់មានអីពន្យល់បន្ថែមទេ ព្រោះអ្វីដែលខ្ញុំជម្រាបពីម្សិលមិញគឺបានបង្ហាញអស់ហើយ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ដើម្បីជាកំណត់ត្រាប្រតិចារឹកទាក់ទងទៅនឹងឈ្មោះ សោ <ដែលយើងទើបបានពិភាក្សាគ្នា>នៅក្នុងចម្លើយរបស់ ឆាំ។ ខ្ញុំចង់ឱ្យអង្គជំនុំជម្រះពិនិត្យមើលឯកសារ <E3/2166> គឺជាបញ្ជីឈ្មោះអ្នកទោស<មួយទៀត>នៅស-២១ មកពីភូមិភាគកណ្ដាល គឺ<នៅលេខរៀងទី១០៦។>

[០៩:៣៣:០២]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា ការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងទាក់ទងទៅនឹងចំណុចនេះ ហាក់ដូចជាមិនត្រូវនឹងកាលៈទេសៈទេ។ ព្រោះយើងកំពុងតែសួរសាក្សី អ៊ីចឹងការដាក់ ការកំណត់សម្គាល់អីផ្សេងនោះ អាហ្នឹងគួរតែចាំពេលក្រោយ។ បាទ សូមអរគុណ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន យើងគ្រាន់តែចង់ជួយអង្គជំនុំជម្រះឱ្យបានប្រកបដោយប្រសិទ្ធភាពបំផុត ហើយខ្ញុំគិតថា តាមបទពិសោធន៍របស់ខ្ញុំ គឺខ្ញុំគិតថាវា<>មានប្រយោជន៍ចំពោះអង្គជំនុំជម្រះ<បើមានលេខយោងក្នុងបរិបទដែលអ្នកណាម្នាក់បានលើកយកមកពិភាក្សា។ ពួកយើងរីករាយផ្ដល់ជូនពេលណាក៏បានបើវាជាប្រយោជន៍ដល់អង្គជំនុំជម្រះ។> ខ្ញុំគិតថា វាចំណាយពេលមិនដល់មួយនាទីផង ក្នុងការដែលខ្ញុំជូនជាព័ត៌មានដល់អង្គជំនុំជម្រះបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែទំនងគ្រាន់តែប្រើឈ្មោះហ្នឹងមិនត្រូវផង ម្សិលមិញឈ្មោះ សៅ ព្រះរាជអាជ្ញារងជាតិហ្នឹងថា សៅ ដល់ពេលព្រះរាជអាជ្ញារងអន្តរជាតិហ្នឹងនៅតែ សោ រហូត។ មួយណា សោ, មួយណា សៅ ឥឡូវនេះ? ឈ្មោះនេះ? ឬក៏ឈ្មោះពីរនាក់ផ្សេងគ្នា?

Deleted: ហើយលោក --

Deleted: គឺ

Deleted: --

Deleted: គឺជាការ

Deleted: ហើយ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[០៩:៣៤:២២]

**លោក ស្រ៊ា រតនះ៖**

សូមជម្រាបឯកឧត្តម -- លោកប្រធានសវនាការ តាមពិតគាត់សំដៅទៅលើឈ្មោះ សោ ប៉ុន្តែគាត់សរសេរ ដោយសារអក្សរឡាតាំង "S-A-O" នៅ -- ហើយនៅពេលនោះទៀត គាត់លើកឡើងទៅអ្នកបកប្រែហាក់ដូចជា ខ្ញុំគិតថា គាត់បកប្រែច្រឡំ ប៉ុន្តែដល់ពេលមើលតាមកំណត់ហេតុនៅ -- របស់អៀង ឆាំ នេះ តាមពិតឈ្មោះ សោ។ អ៊ីចឹងពីម្សិលមិញ ដែលខ្ញុំបញ្ជាក់ថាឈ្មោះ សៅ ហ្នឹង មិនមែនទេ គឺឈ្មោះ សោ។ ខ្ញុំបានធ្វើកំហុសនេះមួយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដែលការបញ្ជាក់ឱ្យបានច្បាស់លាស់ ព្រោះប្របូកច្របល់ឈ្មោះ សៅ ផង ឈ្មោះ សោ ផង មនុស្សតែម្នាក់។ អញ្ជើញបាទ!

**លោក ត្រាវិស ហ្វារះ៖**

សូមអរគុណលោកប្រធាន។ មានឯកសារមួយទៀត ដែលខ្ញុំចង់និយាយយោង ទាក់ទងទៅនឹងបុគ្គលដែលយើងបានពិភាក្សារួចហើយនេះគឺឯកសារ D43/IV-Annex-44 គឺជាចម្លើយសារភាពពីស-២១ របស់ឈ្មោះ យ៉ាប់ យ៉ន ហៅ សោ។ ហើយយើងផ្អែកទៅលើឯកសារនេះ គ្រាន់តែកំណត់ថាគាត់ស្ថិតនៅក្នុងមន្ទីរស-២១។ ហើយឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកាជូនទៅអង្គជំនុំ -- ប្រគល់វេទិកាជូនមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[០៩:៣៦:១២]

**លោកស្រី ម៉ារី ហ្គ្វីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះ ជូនទៅសហភាតារបស់ខ្ញុំ គឺមេធាវី ទី ស្រ៊ីនណា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណ លោកប្រធាន។ ជាដំបូងសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង អង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សូមជម្រាបសួរលោក ប៊ិច សុខា។ ជម្រាបសួរលោក ប៊ិច សុខា លោកឮខ្ញុំនិយាយទេ?

**លោក ប៊ិច សុខា៖**

**ឆ៖** បាទ ឮ លោកស្រី។

**ស៖** នាងខ្ញុំមានសំណួរមួយចំនួនចង់ឲ្យលោកជួយបំភ្លឺ អំពីព្រឹត្តិការណ៍ដែលលោកបានជួបប្រទះ នៅក្នុងពេលដែលលោកធ្វើការនៅក្នុងទំនប់១មករា។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើទំនប់១មករាហ្នឹង មាន ទីតាំងនៅកន្លែងណាដែរលោក?

[០៩:៣៧:០៨]

**ឆ៖** ទំនប់១មករា មានទីតាំងនៅហ្នឹងស្ទឹងជីនិត គេហៅថា នៅក្នុង -- នៅជិតកំពង់ថ្មហ្នឹង ស្រុកបារាយណ៍។

**ស៖** សូមអរគុណ។ ចុះទាក់ទងទៅនឹងការសាងសង់ទំនប់ហ្នឹង គេចាប់ផ្ដើមពីពេលណា ហើយ បញ្ចប់វិញនៅពេលណាដែរលោក?

**ឆ៖** ខ្ញុំចាំបានថា សាងសង់នៅឆ្នាំ១៩៧៧បាទ ប៉ុន្តែបញ្ចប់វិញវាដូចជាធ្វើរហូតមិនទាន់បានចប់ សព្វគ្រប់១០០ភាគរយផងទេ។

**ស៖** សូមអរគុណ។ ហើយចុះនៅក្នុងអំឡុងពេលហ្នឹង អ្នកដែលទទួល ឬក៏អ្នកដែលគ្រប់គ្រង ការដ្ឋានទាំងមូលហ្នឹង មានឈ្មោះអីដែរលោក?

**ឆ៖** គ្រប់គ្រងការដ្ឋានទាំងមូលនៃទំនប់ទាំងអស់ហ្នឹង ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែក្រុមការងារខ្ញុំប្អូន នាក់ប៉ុណ្ណឹង។

[០៩:៣៨:១៧]

**ស៖** សូមអរគុណ។ ហើយអ៊ីចឹង ខ្ញុំសូមបន្តសំណួរទាក់ទងជាមួយនឹងបញ្ហាបច្ចេកទេសនៃ ទំនប់វិញ។ ខ្ញុំចង់សួរលោកថា តើការសាងសង់ទំនប់នេះ គេធ្វើការសាងសង់រួម ពីក្បាលទំនប់រហូតដល់ ទៅដល់ចុងទំនប់ ក្នុងពេលតែមួយតែម្ដង ឬក៏គេធ្វើជាកង់ៗ មានន័យថា គេធ្វើរួចមួយកង់ហើយ ទើប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានគេចាប់ផ្តើមធ្វើមួយកង់បន្តទៀត? លោកអាចជម្រាបជូនអង្គជំនុំជម្រះ អំពីបញ្ហាហ្នឹងបានដែរឬទេ?

**ឆ៖** ទាក់ទងការងារលម្អិតជារួម ខ្ញុំមិនអាចជម្រាបបានទេ តែទាក់ទងនឹងការជំនាញរបស់ខ្ញុំ គឺការងារស្ទង់វាស់ដីប៉ុណ្ណឹង គឺធ្វើចាប់ផ្តើមធ្វើរហូតទល់ដល់ថ្ងៃដែលយើងផ្អាកឈប់ធ្វើនុ៎ង គឺទៅមកៗតែប៉ុណ្ណឹង។ ឯទាក់ទងការងាររួមក្រៅពីហ្នឹង ខ្ញុំក្តាប់អត់បានទេ មិនមែនជាការងាររបស់ខ្ញុំ។

**ស៖** សូមអរគុណ អ៊ីចឹងខ្ញុំសូមបន្តសំណួរទៀត។ ទាក់ទងទៅនឹងការវាស់ស្ទង់របស់លោកវិញ។ លោកថា ជំនាញស្នូលរបស់លោក គឺដើរវាស់ស្ទង់ អ៊ីចឹងខ្ញុំចង់ដឹងថា តើពេលដែលលោកវាស់ស្ទង់ ពេលដែលលោកទៅដល់ការដ្ឋាន១មករាហ្នឹងដំបូង គេតម្រូវឱ្យលោកធ្វើការវាស់ស្ទង់ពីដើមទំនប់ រហូតទៅដល់ចុងទំនប់តែម្តង ឬក៏យ៉ាងម៉េចដែរលោក?

[០៩:៣៩:៤៥]

**ឆ៖** ការងារវាស់ស្ទង់ យើងធ្វើជាបណ្តើរៗទៅរហូត ទាល់ៗតែផុត ប៉ុនមិនមែនធ្វើតែមួយថ្ងៃហ្នឹងហើយ យើងធ្វើម្ងៃបន្តិចៗ តអ៊ីចឹងទៅ ហើយសាចុះសាឡើងនៅក្នុងការងារហ្នឹង។

**ស៖** អ៊ីចឹងមានន័យថា លោកអំឡុងពេលដែលលោកចុះធ្វើហ្នឹងគឺលោកដើរពីដើមទំនប់ ដើរត្រួតពិនិត្យមើលស្ថានភាពដី តាំងពីដើមទំនប់រហូតដល់ចុងទំនប់តែម្តង ឬក៏ម៉េចដែរលោក? មានន័យអ៊ីចឹងមែនទេ?

**ឆ៖** ការធ្វើនេះ ខាងខ្ញុំអត់មានត្រូវដើរត្រួតពិនិត្យទេ គឺប្លង់ចង្អុលស្លាកបង្ហាញមកឱ្យធ្វើម៉េចយើងអនុវត្តទៅតាមប្លង់ហ្នឹង។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសុំបញ្ជាក់លោកបន្ថែមទៀតថា ពេលដែលលោកចុះទៅធ្វើហ្នឹងគឺប្លង់គេចង្អុលមក ពេលដែលចុះទៅហ្នឹង ពេលដែលចុះទៅវាស់ស្ទង់ស្ថានភាពដីហ្នឹង លោកចំណាយរយៈពេលប៉ុន្មានទើបបានធ្វើការវាស់ស្ទង់ដីហ្នឹង ទើបអាចវាស់ស្ទង់ដីហ្នឹងបានលោក?

**ឆ៖** យើងបើគិតទៅ យើងរករយៈពេលបញ្ឈប់អត់ឃើញ ព្រោះយើងត្រូវធ្វើជាប្រចាំ។ ទាល់ដល់ថ្ងៃដែលផ្អាកឈប់គឺពួកខ្ញុំឈប់តែម្តងដែរ។

[០៩:៤១:១៤]

**ស៖** អ៊ីចឹង ខ្ញុំសុំបញ្ជាក់លោកទៀតថា តាំងពីដែលលោកចុះទៅធ្វើហ្នឹង លោកបានទៅទីតាំងកន្លែងណាដែរនៃទំនប់ហ្នឹង? ចុះវាស់វែងនៅទីតាំងត្រង់ទីណាខ្លះដែរ? លោកអាចរៀបរាប់បានទេ?

**ឆ៖** យើងធ្វើៗនៅចំណុចទី១ យើងចាប់ផ្តើមធ្វើនៅនឹងម្តុំស្ទឹងជីនិតហ្នឹងមុនគេ។ បន្ទាប់មកបាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងតៗទៅផ្នែកសងខាង បណ្ដើរៗៗរហូតទាល់ដល់បញ្ចប់ ហើយសាទៅសាមកនៅហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំសុំបន្តសំណួរទៀត តើចំណុច ទាក់ទងនឹងបច្ចេកទេសហ្នឹងដែរ ខ្ញុំចង់ដឹងថាតើការសាងសង់ទំនប់ហ្នឹងមួយ -- សាងសង់ទំនប់មួយ តើនៅក្នុងទំនប់ហ្នឹងវាមានចំណុចស្នូលដែរឬទេ? ចំណុចស្នូលនៃទំនប់ហ្នឹង ឬក៏ជាចំណុចសំខាន់នៃទំនប់ហ្នឹង តើជាចំណុចណាដែរលោក?

**ឆ៖** ចំណុចស្នូលម៉េច? ខ្ញុំអត់យល់។

**ស៖** ខ្ញុំសុំបញ្ជាក់ថា ធម្មតានៅក្នុងទំនប់មួយអ៊ីចឹង វាតែងតែមានចំណុចសំខាន់ជាងគេនៃទំនប់ ឧទាហរណ៍ដូចជាក្បាល ឬក៏កន្ទុយនៃទំនប់។ តើចំណុចកន្លែងដែលសំខាន់ជាងគេលោក?

**ឆ៖** ចំណុចសំខាន់ជាងគេគឺជាអាងទឹកធំ គេហៅថាទំនប់ស៊ីម៉ង់ត៍ ១មករាហ្នឹង ចំណុចសំខាន់ហ្នឹងជាក្បាលស្តុកទឹករបស់វា ប៉ុន្តែការងារនៅកន្លែងទំនប់ធំនេះ គឺមិនមែនជាការងាររបស់ពួកខ្ញុំទេ។

[០៩:៤៣:១២]

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសុំបន្តទៀតថា តើទីតាំងនៃអាងស្តុកធំហ្នឹងគឺនៅត្រង់ចំណុចណាដែរលោក?

**ឆ៖** នៅនឹងស្ទឹងជីនិតហ្នឹងឯង។

**ស៖** សូមអរគុណ។ ពេលហ្នឹង ពេលដែលលោកទៅសាងសង់ --

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អង់តា ហ្គីសសេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោស។ ខ្ញុំមានការកត់សម្គាល់ដូចម្សិលមិញដែរ គឺថាពេលដែលសួរ និងឆ្លើយហ្នឹងអត់មានផ្អាកបន្តិច<ណាសោះ ពីព្រោះ ជាភាសាបារាំង យើងបានបាត់ផ្នែកមុនៗនៃចម្លើយទាំងហ្នឹង>។ <> អ៊ីចឹង សូមលោកស្រីមេធាវីសូមបង្អង់បន្តិចមុននឹងសួរសំណួរ ដើម្បីឱ្យយើងបានស្តាប់ឮការបកប្រែទាំងស្រុង។

Deleted: ទេ

Deleted: អ៊ីចឹង នៅពេលដែលបកប្រែទៅយើងបាត់ចម្លើយបន្តិចបាត់ហើយ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណ។ ខ្ញុំនឹងព្យាយាមធ្វើការបង្អង់នូវការសួរ តាំងសំណួររបស់ខ្ញុំ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** លោក សុខា ខ្ញុំសុំសួរលោកបន្តទៀតពាក់ព័ន្ធជាមួយនឹងនៅពេលដែលលោកទៅសាងសង់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទំនប់ហ្នឹងដំបូងលោក -- គេឲ្យក្រុមរបស់លោកហ្នឹងទៅធ្វើនៅអាងធំហ្នឹងតែម្តង ទៅវាស់វែងស្ទង់ស្ថានភាពនៅអាងធំហ្នឹងតែម្តង ឬមួយក៏ទៅទីតាំងកន្លែងណាផ្សេងនៃទំនប់?

[០៩:៤៥:០២]

**លោក ប៉ិច សុខា៖**

**ឆ៖** ខ្ញុំបានជម្រាបខាងដើមហើយ យើងចាប់ផ្តើមពីសំណង់ធំហ្នឹងទៅ ហើយបានយើងធ្វើបន្ត ៗៗទៅទៀត ផ្នែកស្ទង់វាស់ គឺវាស់តែតួៗទំនប់ និងធ្វើទៅតាមប្លង់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមចង់សុំសួរលោកថា ពេលដែលលោកចុះទៅហ្នឹង ពេលហ្នឹងគឺមានប្រជាជន ឬក៏មានមនុស្សគេចុះទៅធ្វើការងារនៅទំនប់ហ្នឹងហើយ ឬក៏នៅទេលោក?

**ឆ៖** កាលខ្ញុំចុះទៅដំបូងហ្នឹង នៅកន្លែងហ្នឹងគេមានបោះគោល១១១ខ្លះហើយ តែពេលខ្ញុំទៅស្ទង់ហ្នឹងមិនទាន់មានប្រជាជនទៅទេ។

**ស៖** សូមអរគុណ។ ចុះពេលណាដែរដែលទើបបានគេតម្រូវឲ្យប្រជាជនហ្នឹងធ្វើដំណើរទៅសាងសង់ទំនប់ -- ពេលណាដែរដែលគេតម្រូវឲ្យប្រជាជនហ្នឹងទៅសាងសង់ទំនប់នោះ? លោកចាំបានដែរឬទេ?

**ឆ៖** ខ្ញុំរកចាំថ្ងៃខែមិនបានទេ ប៉ុន្តែដឹងថាឆ្នាំ៧៧ហ្នឹង ដូចគ្នា គ្រាន់តែខ្ញុំមុនបន្តិច។

**ស៖** ខ្ញុំសូមសួរបន្តទៀត។ ឆ្លងតាមការសង្កេតរបស់លោកវិញ ថាតើនៅពេលដែលលោកទៅធ្វើនៅអាងស្តុកទឹកធំហ្នឹង តើពេលហ្នឹង ពេលដែលប្រជាជនទៅហ្នឹង ពេលហ្នឹងគេចាប់ផ្តើមហៅប្រជាជនធ្វើឲ្យទៅធ្វើទំនប់ហ្នឹងមានចំនួនប្រហែលជាប៉ុន្មាននាក់ដែរពីដំបូងអ៊ីចឹង? មានចំនួនចាប់ផ្តើមច្រើនតែម្តង ឬមួយក៏មានតែបន្តិចបន្តួចនៅឡើយទេ ឬក៏យ៉ាងម៉េចដែរស្ថានភាពនៅពេលហ្នឹង? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ?

[០៩:៤៧:២៧]

**ឆ៖** បញ្ហាហ្នឹងខ្ញុំក្តាប់មិនបានទេ ព្រោះអីវាកន្លែងគេនៅច្រើនដែរ ប៉ុន្តែគ្រាន់ដូចខ្ញុំជម្រាបពីម្សិលមិញអ៊ីចឹង ខ្ញុំទទួលព័ត៌មានតាមការអង្គុយស្តាប់នៃការបើកការដ្ឋានមានចំនួនដូចខ្ញុំនិយាយម្សិលមិញ តែគ្រាន់តែមកម្តងប្រាប់ទាំងអស់ ក៏ខ្ញុំមិនដឹងព្រោះការងារខ្ញុំអត់នៅនឹងកន្លែងសោះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តសំណួរទៀត សួរថាតើលោកថាលោកដើរ -- ការងាររបស់លោកគឺជាការងារដើរចល័តមិននៅនឹងកន្លែងទេ ហើយពេលហ្នឹងលោកថាមានមនុស្សធ្វើការច្រើនតែ

ម្តង ហើយអ៊ីចឹងខ្ញុំចង់សួរលោក ថាតើពេលដែលលោកដើរហ្នឹង លោកដើរទៅកន្លែងណា? ហើយនៅក្នុងមួយកន្លែងដែលលោក -- មួយកន្លែងៗដែលលោកដើរទៅហ្នឹង លោកចំណាយពេលរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ធម្មតាទេ ដើរចល័តទៅមួយកន្លែងរយៈពេលចម្ងាយពីចំណុចមួយទៅចំណុចមួយដែលមានរយៈពេលដូរកន្លែងស្នាក់នៅហ្នឹង វាមានចម្ងាយវាប្រហែលជា១០គីឡូ។ អ៊ីចឹងក្នុងមួយកន្លែងៗ យើងអាចនៅបួនប្រាំថ្ងៃ យើងផ្ទេរទៅផ្ទេរមកអ៊ីចឹង។ វាអត់មាននៅថេរមួយកន្លែងបានទេ។

[០៩:៤៩:១០]

**សៈ** អ៊ីចឹងខ្ញុំសូមសួរលោកបន្តទៀតថា នៅក្នុងមួយកន្លែង -- តើលោកអាចចាំទេថាកន្លែងដែលលោកទៅហ្នឹងមានឈ្មោះអីដែរខ្លះទេលោក?

**ឆ៖** អូ! ចាំអត់បានទេ។ ភូមិសាស្ត្រទីនោះ ខ្ញុំមិនដែលស្គាល់ផង។

**សៈ** អ៊ីចឹងខ្ញុំសូមសួរអំពីទិដ្ឋភាពការងារដែលៗប្រជាជនគាត់ធ្វើនៅតាមទីតាំងមួយកន្លែងៗដែលលោកទៅវិញ។ ពេលដែលលោកទៅដល់កន្លែងមួយ លោកថាលោកស្នាក់នៅរយៈពេលប្រាំថ្ងៃអ៊ីចឹងមែនទេលោក? អ៊ីចឹងខ្ញុំចង់សួរលោកថា តើពេលហ្នឹងលោកឃើញ -- តាមការសង្កេតរបស់លោកហ្នឹង លោក -- តើស្ថានភាពនៅពេលនោះ វាយ៉ាងម៉េចដែរ ទាក់ទងនឹងការងារធ្វើការរបស់ប្រជាជន? ស្ថានភាពធ្វើរបស់គាត់ហ្នឹងយ៉ាងម៉េចដែរ? ទាំងប្រជាជនទាំងអស់ហ្នឹង គាត់ដូចថាគាត់មានការសកម្មជាមួយនឹងការងារទាំងនោះដែរឬទេ?

**ឆ៖** តាមភ្នែកខ្ញុំសម្លឹងមើលទៅឃើញពួកគាត់នៅធ្វើការអ៊ីចឹង ប៉ុនគ្រាន់ថាសកម្ម មិនសកម្មម៉េច ខ្ញុំមិនបានដឹងទេ។

[០៩:៥០:៣៥]

**សៈ** សូមអរគុណ។ អ៊ីចឹងឆ្លងតាមការសង្កេតរបស់លោកហ្នឹង តើស្ថានភាពដូចជារូបរាងកាយជាពិសេសទាក់ទងនឹងរូបរាងកាយរបស់ប្រជាជនវិញ យ៉ាងម៉េចដែរ?

**ឆ៖** តាមខ្ញុំមើលឃើញនឹងភ្នែកដូចជាធម្មតាទេ។

**សៈ** សូមលោកជួយបញ្ជាក់បន្ថែមបន្តិចបានទេ ពាក្យថា "ធម្មតា" របស់លោកហ្នឹង លោកសំដៅទៅលើយ៉ាងម៉េចដែរ? ព្រោះអីដូចជាឧទាហរណ៍ថា "ធម្មតា" ហ្នឹងមានន័យថាគាត់មានកម្លាំងកាយ គាត់ធាត់ ឬក៏គាត់ស្គម ឬក៏យ៉ាងម៉េចដែរលោក? សូមជួយបញ្ជាក់ត្រង់ចំណុចនេះបន្តិច តើបាន

ដែរឬទេ?

**ឆ៖** ពាក្យថា "ធម្មតា" ភ្នែកយើងសម្លឹងឃើញទៅ ឃើញថាពួកគាត់ហ្នឹងធ្វើការធម្មតា វាមិនឃើញដួលប្រកាច់ប្រកិនអី នៅហ្នឹងផង។

[០៩:៥១:៤៨]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរលោកត្រឡប់មកអាងស្តុកទឹកវិញ ដែលជាចំណុចដំបូងដែលលោកទៅដល់។ នៅកន្លែងចំណុចដំបូងដែលលោកទៅដល់ហ្នឹងគឺ តើលោកមានចាំបានដែរឬទេ ថាតើនៅក្នុងអំឡុងពេលហ្នឹង មានអ្នក មនុស្សដែលធ្វើការនៅទីនោះច្រើន ឬក៏តិចលោក? ហើយមានចំនួនប្រហែលជាប៉ុន្មានដែរ បើតាមការសង្កេតរបស់លោក?

**ឆ៖** និយាយចំនួននោះ វាមិនដឹងថាប៉ុន្មានទេ ប៉ុនថាមើលទៅឃើញច្រើន។

**ស៖** ចុះស្ថានភាពការងារនៅអាងស្តុកទឹក អាងធំហ្នឹងវាមានលក្ខណៈយ៉ាងម៉េចដែរ? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** ការងារលម្អិតហ្នឹង ខ្ញុំក្តាប់អត់បានទេ ព្រោះវាខុសពីកន្លែងរបស់ខ្ញុំធ្វើការ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ជាមួយលោកត្រង់ចំណុចមួយទៀត ឆ្លងតាមការសង្កេតរបស់លោកដែរហ្នឹង ខ្ញុំចង់សួរលោកថា តើពេលហ្នឹង ប្រជាជនដែលគេមកធ្វើការនៅទំនប់១មករាហ្នឹង ភាគច្រើនគឺជាអ្នកដែលស្ម័គ្រចិត្តមកធ្វើការដោយខ្លួនឯង ឬក៏ដោយមានការបង្ខិតបង្ខំពីខាងណាដែរ ឬក៏អត់លោក?

[០៩:៥៣:២៧]

**ឆ៖** អូ៎! ការងារហ្នឹងកាន់តែឆ្ងាយទៀត ខ្ញុំអត់ដឹងសោះ។

**ស៖** សូមអរគុណ អ៊ីចឹងខ្ញុំសូមបន្តសំណួរពាក់ព័ន្ធជាមួយនឹងសិទ្ធិសេរីភាពរបស់ប្រជាជនវិញ។ តើនៅក្នុងអំឡុងពេលដែលប្រជាជនធ្វើការនៅក្នុងការដ្ឋាន ១មករាហ្នឹង ពួកគាត់មានសិទ្ធិសេរីភាពនៅក្នុងការនិយាយស្តីដែរឬទេលោក? ដូចជាការនិយាយប្រាស្រ័យទាក់ទងគ្នា ឬមួយក៏ការនិយាយផ្តល់មតិយោបល់ទៅលើចំណុច ដូចការ ចំណុចការងារដែលពួកគាត់កំពុងធ្វើ តើគាត់មានសិទ្ធិសេរីភាពក្នុងការនិយាយដែរឬទេលោក?

**ឆ៖** ការនិយាយគ្នាគាត់ហ្នឹង មានសិទ្ធិគ្រប់គ្រាន់ មិនគ្រប់គ្រាន់ ខ្ញុំមិនដឹងទេ ព្រោះឃើញគាត់និយាយគ្នាធម្មតាក្នុងការងារ។ គ្រាន់តែយើងឃើញ ព្រោះយើងមិនមែនអ្នកទៅសង្កេត ទៅស្តាប់អីរឿង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងផង។

**ស៖** សូមអរគុណ។ ចុះចំពោះរូបលោកវិញ ថាតើលោក ការនិយាយស្ដី ការនិយាយគ្នារបស់លោកហ្នឹង លោកមានសិទ្ធិនៅក្នុងការនិយាយប្រាស្រ័យទាក់ទងរឿងការងារដែរឬទេ? ឧទាហរណ៍ថា ការងារហ្នឹងវាអ៊ីចេះវាអ៊ីចុះ ដូចថាបើសិនជាធ្វើអ៊ីចេះដើម្បីឱ្យវាល្អ ទំនប់ហ្នឹងល្អគួរតែធ្វើអ៊ីចេះ ហើយទំនប់ហ្នឹងបើសិនធ្វើអ៊ីចេះទៅនាំឱ្យមានបញ្ហាកើតឡើង។ តើលោកមានសិទ្ធិរិះគន់បែបហ្នឹងដែរឬទេ?

**ឆ៖** សម្រាប់ខ្ញុំវិញ ខ្ញុំអត់មានអីគិតដល់នុ៎ងទេ គិតថាប្រឹងធ្វើម៉េចថា ការងារថ្នាក់លើគេឱ្យធ្វើការស្ទង់វាស់ហ្នឹង គឺគិតតែរឿងបច្ចេកទេសខ្លួនឯងប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងដោយសារលោកថាជាអ្នកបច្ចេកទេសអ៊ីចឹង ខ្ញុំចង់សុំសួរបញ្ជាក់ទៀតថា លោកមានសិទ្ធិក្នុងការបញ្ចេញយោបល់ទៅលើបញ្ហាបច្ចេកទេសហ្នឹងដែរឬទេ?

**ឆ៖** ក្រុមប្អូននាក់យើងមានការពិភាក្សាគ្នាទៅលើប្លង់ហ្នឹង មានយើងពិភាក្សាគ្នាទៅលើការងារបច្ចេកទេសថា យើងត្រូវធ្វើថ្ងៃណេះទៅចំណុចណា អីចំណុចណាអ៊ីចឹង។ គឺមេក្រុមហ្នឹងគេហៅគ្នាពិភាក្សា។ ហើយយើងធ្វើហ្នឹងគិតធ្វើយ៉ាងម៉េចឱ្យទៅតាមប្លង់ គឺនិយាយគ្នាតែរឿងប៉ុណ្ណឹងទេ។

[០៩:៥៦:២៤]

**ស៖** សូមអរគុណ។ ក្រោយពីលោកពិភាក្សាគ្នាថាឱ្យគេធ្វើទៅតាមប្លង់របស់លោកហ្នឹង តើលោក ឬក៏នរណាជាអ្នកដើរប្រាប់ទៅអ្នកក្រុមដែលគេអនុវត្តការងារទៅតាមប្លង់របស់លោកហ្នឹង? តើលោកជាអ្នកដើរទៅប្រាប់គេ ឬក៏យ៉ាងម៉េចដែរលោក? ឬក៏មានអ្នកផ្សេងគេដើរទៅប្រាប់អ្នកដែលត្រូវធ្វើទៅតាមប្លង់របស់លោកកំណត់នោះ?

**ឆ៖** ការងារន័យដែលខ្ញុំនិយាយអំមិញនេះ គឺអត់មានសំដៅខាងខ្ញុំទៅបញ្ជាអ្នកនេះ អ្នកនោះទេ ក្នុងក្រុមខ្ញុំត្រូវធ្វើម៉េចត្រួតពិនិត្យនូវការងារប្រចាំថ្ងៃរបស់ខ្លួន។ ថាធ្វើបានប៉ុនណា ខុសកន្លែងណា បង្គោលកន្លែងណាដួលយើងត្រូវកែឡើងវិញ គឺការងារពួកខ្ញុំតែប៉ុណ្ណឹងឯង។ ឯការងារបញ្ជា បង្គាប់អីទៅលើគេទេ គ្មានទេ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរអំពីសិទ្ធិសេរីភាពនៅក្នុងការដើរហើរវិញ។ តើប្រជាជនដែលធ្វើការនៅក្នុងការដ្ឋានហ្នឹងគាត់មានសិទ្ធិសេរីភាពនៅក្នុងការហើរ ដូចថាគាត់ប្ដូរទីតាំងដែរឬទេមើលទៅ? ដូចថាគាត់ចង់ប្ដូរថា ថ្ងៃនេះគាត់ធ្វើនេះហត់ណាស់ គាត់សូមទៅធ្វើកន្លែងផ្សេងវិញទៀត។ តើគាត់អាចធ្វើអ៊ីចឹងបានដែរឬទេលោក?

[០៩:៥៧:៤៥]

**ឆ៖** អាហ្នឹង ខ្ញុំភ្លេចអត់បានទេ។

**ស៖** ខ្ញុំសូមសួរលោកពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងារវិញ។ ថាតើរវាងបុរស និងស្ត្រីហ្នឹង គេបែងចែកឱ្យធ្វើការងារយ៉ាងដូចម្តេចដែរលោកនៅពេលនុ៎ង?

**ឆ៖** អ៎! ការងារហ្នឹងខ្ញុំ ហៅថាជម្រៅទៅដល់ហ្នឹង ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកថា តាមរយៈការសង្កេតរបស់លោកហ្នឹង តើលោកមានដឹងថាបុរស មនុស្សប្រុស ឬក៏មនុស្សស្រីហ្នឹងគេឱ្យធ្វើការរួមគ្នា ឬមួយគេឱ្យធ្វើការដាច់ដោយឡែកពីគ្នា? ហើយការ--

**ប្រធានអង្គជំនុំ៖**

លោក ប៉ិច សុខា ឆ្លើយ លោក ប៉ិច សុខា!

**លោក ប៉ិច សុខា៖**

បាទ លោកប្រធាន ខ្ញុំភ្លេចសំណួរហ្នឹងអត់បានអំមិញ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីតាំងសំណួរចុងក្រោយរបស់លោកស្រីសាជាថ្មីម្តងទៀត។

[០៩:៥៩:៣៧]

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ខ្ញុំចង់សួរលោកថា ឆ្លងតាមការសង្កេតរបស់លោកហ្នឹងទាក់ទងទៅនឹងមនុស្សប្រុសហើយ និងមនុស្សស្រី តើគេឱ្យធ្វើការរួមគ្នា ឬគេឱ្យធ្វើការដាច់ដោយឡែកពីគ្នា ឆ្លងតាមការសង្កេតរបស់លោក នៅអាងទំនប់ ១មករា អាងស្តុកទឹកធំហ្នឹង?

**លោក ប៉ិច សុខា៖**

**ឆ៖** តាមខ្ញុំសង្កេតមើលឃើញទៅវាមិនដាច់ដោយឡែកទេ ព្រោះឃើញពួកគាត់ធ្វើការនៅជុំៗគ្នាដែរ។

**ស៖** ចុះឆ្លងតាមការសង្កេតរបស់លោកផងដែរហ្នឹង ថាតើពេលហ្នឹងមនុស្សស្រីហ្នឹងគេឱ្យគាត់ធ្វើអីគេខ្លះ? លោកចាំបានដែរឬទេ?

**ឆ៖** រឿងឱ្យធ្វើអីចែកដាច់ មិនដាច់ ខ្ញុំមិនដឹងទេ ប៉ុន្តែឃើញតែពួកគាត់ធ្វើការដូចគ្នា ស្រីក៏មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វែកដី ប្រុសក៏មានវែកដី មិនដឹងថាដាច់អាម៉េច ខ្ញុំអត់ដឹងដែរ។

[១០:០០:៤៩]

**ស៖** សូមអរគុណ។ អ៊ីចឹងនៅក្នុងពេលដែលគេធ្វើការងារ -- កំពុងសាងសង់អាងស្តុកទឹកហ្នឹង តើមានល្បប ឬក៏សន្តិសុខអីឈរយាមកាមនៅទីនុំងដែរឬទេ?

**ឆ៖** យើងមើលទៅអ្នកយាមកាមរបៀបដូចថា ប្រុងប្រយ័ត្នអីហ្នឹង ដូចមិនឃើញមានផង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរសំណួរមួយទៀតពាក់ព័ន្ធជាមួយនឹងវត្តអារាមវិញ។ តើលោកនៅក្បែរអាង -- ក្បែរការដ្ឋាននុំងវាមានវត្តអារាមដែរឬទេលោក?

**ឆ៖** កន្លែងដែលខ្ញុំធ្វើការហ្នឹង ដូចជាមិនមានវត្តអារាមអី សូម្បីតែភូមិនៅក្នុងចំណុចហ្នឹងក៏វាមិនមានឃើញផង។

**ស៖** ចុះនៅត្រង់កន្លែងស្ទឹងជីនិត លោកធ្លាប់ដែលឮ ឬក៏ឃើញវត្តអីដែលនៅក្បែរៗស្ទឹងជីនិតដែរឬទេ?

**ឆ៖** រឿងខ្ញុំឲ្យដើរទៅដល់វត្តដល់អី ដូចមិនដែលបានទៅដល់ទេ ខ្ញុំនៅតែកន្លែងការដ្ឋានការងាររបស់ខ្ញុំប៉ុណ្ណឹង។

[១០:០២:២៤]

**ស៖** ចុះ ខ្ញុំសុំសួរលោកបញ្ជាក់ទៀតថា នៅក្នុងពេលដែលលោកធ្វើការនៅក្នុងការដ្ឋានទាំងមូលហ្នឹង តើមានដែលដឹង ឬក៏ឮគេធ្វើការស៊ើបអង្កេតរកខ្មាំង សេ.អ៊ី.អា ឬ កា.ហ្សេ.បេ អីដែរឬទេលោក?

**ឆ៖** អត់ដែលដឹងទេខ្ញុំ រឿងហ្នឹង។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណ ខ្ញុំសូមបញ្ចប់សំណួរត្រឹមនេះ និងសូមផ្ទេរវេទិកានេះជូនទៅលោកស្រី ម៉ារី ហ្គីរ៉ូដ៍។ សូមអរគុណលោកប្រធាន និងសូមអរគុណលោកសាក្សីផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហមេធាវីនាំមុខអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

[១០:០៣:១១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ សូមអរគុណដែលលោកឆ្លើយទៅនឹងសំណួររបស់យើង ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមេធាវីអន្តរជាតិតំណាងឲ្យផលប្រយោជន៍នៃក្រុមជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរទៅលោកអំពីបទពិសោធន៍របស់លោក នៅពេលដែលលោកធ្វើការនៅការដ្ឋានសាងសង់ទំនប់ ១មករា។ ជាបឋម ខ្ញុំចង់លោកឆ្លើយតបទៅនឹងចម្លើយដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត នៅពេលដែលគេសម្ភាសលោកនៅខែតុលា ឆ្នាំ២០០៥។ ខ្ញុំសូមយោងទៅលើឯកសារ E3/403 ERN ជាភាសាបារាំងគឺ 00422238, ERN ជាភាសាខ្មែរ 00389522, ERN ជាភាសាអង់គ្លេស 00403004។ លោកសាក្សីនៅពេលនោះគេសួរលោកថា៖ “តើទំនប់នេះ មានផែនការធ្វើរយៈពេលប៉ុន្មានឆ្នាំឲ្យរួច?” នៅពេលនោះលោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក៖ “ផែនការនេះ ថ្នាក់លើដាក់ឲ្យធ្វើឲ្យចប់ក្នុងរយៈពេលមួយឆ្នាំ ប៉ុន្តែធ្វើមិនទាន់ចប់តាមផែនការនោះទេ”។ <ដូច្នេះ> ខ្ញុំចង់សួរលោកថា តើលោកអាចជម្រាបឲ្យបានលើសពីហ្នឹងទៀតទេថា តើការដ្ឋានហ្នឹងប្រើពេលច្រើនជាងការគ្រោងទុក ឬក៏តិចជាងពេលដែលបានគ្រោងទុក?

Deleted: គ្រោង

**ឆ៖** អ្វីដែលជាចម្លើយរបស់ខ្ញុំ ខ្ញុំស្របទៅតាមកំណត់ហេតុ តែពេលវេលានោះដូចបានបង្ហាញអំមិញហើយ គឺយើងគិតថា វាមិនធ្វើទៅតាមគ្រោងទុកទេ។

[១០:០៥:៥១]

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេ ថាតើការសាងសង់ហ្នឹង ចំណាយពេលលើសពីមួយខែ -- មួយឆ្នាំដែលបានគ្រោងទុកហ្នឹង <ឬក៏ចំណាយពេលតិចជាង> ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំបានជម្រាបខាងដើមអំមិញហើយថា វាមិនធ្វើទៅបានទៅតាមផែនការទេ វាធ្វើបន្លាយហួសពីផែនការ មិនទាន់ហើយ។

**ស៖** នៅពេលដែលលោកធ្វើជាអ្នកវាស់ស្ទង់ដីនៅទីនោះ តើលោកគិតថា ការដែលធ្វើគោរពឲ្យទៅតាមផែនការ និងការកំណត់ឲ្យមួយឆ្នាំនោះ វាមានសម្ពាធទេ?

**ឆ៖** ខ្ញុំគិតថា ដូចមិនមានសម្ពាធអីទេ។ វាធ្វើ -- យើងធ្វើរហូតទៅ ដល់វាមិនហើយ យើងធ្វើតទៀតទៅ ឲ្យមានសម្ពាធអីទេ ដូចមិនមាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងមានន័យថា លោកត្រូវធ្វើការច្រើន ហើយពេលម៉ោងធ្វើការនោះ ក៏វែងជាងមុនដែរ ដើម្បីធ្វើយ៉ាងម៉េចឲ្យគោរពទៅតាមផែនការដែលគេដាក់ចុះមកហ្នឹង?

**ឆ៖** អាហ្នឹងវាអ៊ីចឹងហើយ គឺចេះតែធ្វើតទៅទៀតទៅ។

**ស៖** សូមអរគុណ។ មុនលោកបន្តិចនេះ យើងបានស្ដាប់ចម្លើយរបស់សាក្សីមួយដែលជាមេកងមួយរូប នៅការដ្ឋានសាងសង់ទំនប់១មករា។ គាត់ក៏ជាមេភូមិព្រៃស្រង៉ែ ដែលជាភូមិមួយដែលស្ថិតនៅជិតទំនប់១មករា។ <ក្នុងអំឡុងពេលសវនាការ> សាក្សីរូបនោះបានឆ្លើយថា គាត់បានចូលរួម -- គាត់បានឃើញមានការបាក់ដី<នៅការដ្ឋានទំនប់> ហើយនៅពេលដែលបាក់ដីនុ៎ង នាំឲ្យកម្មករបីនាក់<ក្នុងកងគាត់>ស្លាប់។ តើលោកមានបានឃើញ<គ្រោះថ្នាក់នៅការដ្ឋាននោះទេ? ហើយតើមាន>ការបាក់ដីបែបហ្នឹង នៅទំនប់ ១មករាទេ នៅពេលដែលលោកធ្វើការនៅទីនោះ?

[១០:០៨:៤៧]

**ឆ៖** បាក់ដីត្រង់ណា ខ្ញុំអួចអត់ដឹងផង ព្រោះខ្ញុំមិនសូវនៅហ្នឹងកន្លែងហ្នឹងជាប់ផង។

**ស៖** សូមអរគុណ។ លោកសាក្សី ខ្ញុំចង់ឲ្យលោក<មានប្រតិកម្ម>ទៅនឹងចម្លើយមួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះ ហើយគាត់បានចូលរួមនៅក្នុងនីតិវិធី ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី។ គាត់<ជាសមាជិកម្នាក់>នៅក្នុងកងចល័ត នៅជិតអាងទំនប់១មករា។ ខ្ញុំសូមយោងទៅលើឯកសារ E3/5120, ERN ជាភាសាបារាំង គឺ00940161, ERN ជាភាសាខ្មែរ 00584860, ERN ជាភាសាអង់គ្លេស 00937096។ ខ្ញុំសូមអានឃ្លាមួយនៃសក្ខីកម្មរបស់គាត់ ហើយខ្ញុំចង់ឲ្យលោក<មានប្រតិកម្ម>ទៅនឹងចម្លើយរបស់គាត់។ គាត់ស្ថិតនៅក្នុងកងចល័តមួយនៅក្បែរអាងទឹក ហើយគាត់បានឆ្លើយដូចតទៅ៖ "ខ្ញុំឃើញហេតុការណ៍បាក់ទំនប់នៅទីនោះ ពេលដែលយើងបានជីកអាងបានជ្រៅបានប្រហែលជា១០ម៉ែត្រ។ <ទោះបីមានហេតុការណ៍អ៊ីចឹងហើយ> គេ<នៅតែ>ឲ្យមនុស្សចូលក្នុងអាងនោះ ដើម្បីជីកតទៅទៀត។ អ្នកដែលចូលទៅក្នុងនោះមានច្រើនណាស់ គឺអាចដល់រាប់រយនាក់។ ពេលនោះប្រហែលជាស៊ីម៉ង់ត៍ធ្វើអាងនោះមិនទាន់រឹង ហើយទឹកបុកមកខ្លាំង ធ្វើឲ្យបាក់មាត់អាង ធ្វើឲ្យមនុស្ស<មួយចំនួន>ស្លាប់។ ក្រុមខ្ញុំធ្វើការនៅលើមាត់អាង ខ្ញុំរត់<រួច>ចេញមក ហើយខ្ញុំយំ ភ័យខ្លាំងណាស់។ គេប្រាប់ខ្ញុំថាកុំឲ្យ<រាយការណ៍ពីរឿងនេះ>។ ពេលលើកទំនប់នោះ ពួកខ្មែរក្រហមនិយាយថា មនុស្សច្រើនពេក ឲ្យស្លាប់ខ្លះទៅ កុំឲ្យចង្អៀតដីពេក"។ លោកសាក្សី ខ្ញុំចង់ដឹងថា តើលោកធ្លាប់ឮគេនិយាយអំពីបញ្ហាបែបហ្នឹង ដែលកើតឡើងនៅទំនប់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Indent: Left: 0.51", First line: 0.47", No widow/orphan control, Tab stops: Not at 0.49"

**Deleted:** ¶

**Deleted:** ឆ្លើយតប

**Deleted:** ស្ថិត

**Deleted:** ឆ្លើយតប

**Deleted:** ដែលនៅក្នុងនោះ

**Deleted:** និយាយ

[១០:១១:៤០]

**ឆ៖** បាទ សូមអរគុណ។ ទាក់ទងការងារនេះ បើខ្ញុំអង្គុយគិត សម្រាប់ខ្ញុំវិញ ខ្ញុំអត់ដឹងទេ។ ក្រែងលោពេលវេលាណា វាអាចថាខ្ញុំអត់នៅ ទៅឆ្ងាយម៉េច ក៏ខ្ញុំមិនដឹងដែរ។ មិនឆ្លើយនេះ យករួចខ្លួនទេ តែខ្ញុំអត់ដឹងមែន។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកចាំថា មានបញ្ហាអ្វីផ្សេងទៀតពាក់ព័ន្ធនឹងកំហុសបច្ចេកទេសក្នុងការសាងសង់ទំនប់ហ្នឹងទេ? លោកមាននឹកឃើញថាប្រហែលជាអាចមានបញ្ហាបច្ចេក-ទេសអីពាក់ព័ន្ធនឹងការសាងសង់ទេ?

**ឆ៖** ទាក់ទងរឿងការងារផ្នែកសំណង់បេតុង អាទំនប់ធំអីហ្នឹង ខ្ញុំមិនមែនជាការងារខ្ញុំទេ ខ្ញុំដឹងថាដើរវាស់ ដូចខ្ញុំជម្រាបលោកតុលាការតាំងពីដំបូងមក។ ភារកិច្ចខ្ញុំមានតែដើរវាស់ស្ទង់ បោះបង្គោលការងារខ្ញុំប៉ុណ្ណឹង ពិភាក្សាគ្នាលើការងារហ្នឹង។ ឯបើទាក់ទងរឿងការងារខុសពីការងារហ្នឹងខ្ញុំ គឺខ្ញុំអត់ដឹងទេ។

[១០:១៣:០៦]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងដកស្រង់នូវឃ្លាផ្សេងទៀតនៃចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅខែតុលា ឆ្នាំ២០០៩ គឺឯកសារដែលគឺ E3/403។ ខ្ញុំសូមយោងទៅលើ ERN ជាភាសាបារាំងគឺ 00422242, ERN ជាភាសាអង់គ្លេស 00403007, ERN ជាភាសាខ្មែរ 00389525។ ខ្ញុំសូមអានសំណួរដែលគេសួរលោកនៅសម័យនោះ និងចម្លើយរបស់លោក បន្ទាប់មកខ្ញុំនឹងសួរបន្តទៅនឹងចម្លើយរបស់លោកដែលលោកឆ្លើយនៅពេលនោះ។ នៅពេលនោះគេសួរលោកដូចតទៅ៖ “តើលោកមានឃើញសន្តិសុខ ឬកងឈ្លបដើរពិនិត្យតាមកន្លែងធ្វើការដែរឬទេ?” លោកបានឆ្លើយនៅពេលនោះដូចតទៅ៖ “អត់មានឈ្លបទេ”។ អម្បាញ់មិញនេះលោកក៏បានឆ្លើយអ៊ីចឹងដែរ ថាអត់មានឈ្លបទេ។ “មានតែកងទ័ពភូមិភាគ តែមិនច្រើនទេ គឺពួកគេដើរល្បាតការដ្ឋានសំណង់ខ្លាចខ្មាំងមកបំផ្លាញសមិទ្ធផល។ គេអត់មានដែលរំខានយើងទេ សូម្បីតែបាញ់ផ្លូងផាំងក៏អត់មានដែរ។ ម្យ៉ាងទៀតខ្ញុំក៏មិនដែលឃើញមានការបាញ់សម្លាប់មនុស្សដែរ”។ នៅក្នុងចម្លើយនេះលោកបានបញ្ជាក់ថា មានកងទ័ពភូមិភាគ ដែលមានវត្តមាននៅលើការដ្ឋាន។ ខ្ញុំចង់ដឹងថានៅសម័យនោះ ហេតុអីបានជាលោកដឹងថាកងទ័ពហ្នឹង ជាកងទ័ពមកពីភូមិភាគ?

[១០:១៥:១៨]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ដឹងហ្នឹងដោយសារឮគេនិយាយថា កងទ័ពហ្នឹងមកពីភូមិភាគហ្នឹង យើងចាំបានប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយថាកងទ័ពដើរល្បាតការដ្ឋានសំណង់ហ្នឹង លោកអាចបញ្ជាក់ឱ្យបានច្បាស់ជាងហ្នឹងបន្តិចបានទេ ថាដើរល្បាតហ្នឹង គាត់ធ្វើអីខ្លះទៅ?

**ឆ៖** រឿងលម្អិតជម្រៅអីខ្លឹមសារអី ខ្ញុំមិនអាចបកស្រាយបានទេ ព្រោះអាហ្នឹង ខ្ញុំអត់យល់ដែរ ប៉ុន្តែគ្រាន់តែឃើញគេដើរធម្មតាប៉ុណ្ណឹង ដើរល្បាត ដើររបៀបយាមអីចឹង។ ប៉ុន្តែមិនដឹងន័យគេយ៉ាងម៉េចដើម្បីអី ខ្ញុំក៏មិនជ្រៅដែរ។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកហ្នឹងថាពួកគេមានកាំភ្លើង ក៏ប៉ុន្តែគេមិនដែលបាញ់ផ្លូងផាំងអីទេ តើលោកអាចបញ្ជាក់បានទេថា ពួកកងទ័ពភូមិភាគហ្នឹងកាន់កាំភ្លើងអីដែរ?

**ឆ៖** ដល់ភ្នែកខ្ញុំឃើញមានឃើញអី ខ្ញុំស្គាល់តែកាំភ្លើង អា.កា ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកទៅនឹងអ្នកស៊ើបអង្កេតហ្នឹង លោកនិយាយថា "កងទ័ពដើរល្បាតខ្លាចខ្មាំងមកបំផ្លាញសមិទ្ធផល"។ ខ្ញុំចង់ដឹងថាតើលោកមានន័យថាយ៉ាងម៉េច "ខ្មាំង" នេះ កន្លែងនេះ លោកចង់សំដៅលើអ្នកណាដែរថាជាខ្មាំងដែលកងទ័ពត្រូវៗដើរល្បាតមើលនោះ?

**ឆ៖** អារឿងខ្មាំងហ្នឹង អាហ្នឹងយើងឮតៗគ្នាទេ គេធ្វើអី គេថាដើរការពារក្នុងន័យអំមិញប៉ុណ្ណឹង ប៉ុន្តែត្រង់ខ្មាំងហ្នឹង អ្នកណាខ្មាំង ខ្ញុំមិនដឹងទេ។

[១០:១៧:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ប៊ុច សុខា ឥឡូវនេះដល់ពេលសម្រាកហើយណ៎ា សូមលោកសម្រាកបន្តិច ហើយរហូតដល់ម៉ោងដប់ និងសាមសិបប្រាំនាទី សឹមយើងបន្តកិច្ចដំណើរការសវនាការតទៅទៀត។

សម្រាកចុះ!

**លោក ប៊ុច សុខា៖**

បាទ អរគុណលោកប្រធាន។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង១០:១៨នាទី ដល់ម៉ោង ១០:៣៨នាទី)*

[១០:៣៨:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

បាទ សួស្តីសាក្សី តើត្រៀមខ្លួនហើយនៅ? សួស្តីលោក ប៉ិច សុខា!

**លោក ប៉ិច សុខា៖**

*(ឮមិនច្បាស់)*

**ប្រធានអង្គជំនុំ៖**

លោក ប៉ិច សុខា ត្រៀមខ្លួនហើយនៅ?

សួស្តីលោក ប៉ិច សុខា!

**លោក ប៉ិច សុខា៖**

*(ឮមិនច្បាស់)*

*(មានបញ្ហាបច្ចេកទេស)*

[១០:៤១:២៦]

**ប្រធានអង្គជំនុំ៖**

សួស្តីលោក ប៉ិច សុខា!

**លោក ប៉ិច សុខា៖**

ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងបន្តការងាររបស់យើងតទៀតណ៎ា ទ្អាលនឹងឆាប់ចប់។

**លោក ប៉ិច សុខា៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ប្រគល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៤១:៥០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** ជម្រាបសួរសាជាថ្មីម្តងទៀតលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ។ ខ្ញុំមានសំណួរខ្លីៗ បន្តិចបន្តួច។ អម្បាញ់មិញនេះយើងឈប់សម្រាក ហើយមុនហ្នឹងយើងនិយាយអំពីវត្តមានរបស់កងទ័ព ភូមិភាគ ដែលដើរល្បាតនៅការដ្ឋាន ហើយមានកាន់កាំភ្លើង អាកា៤៧។ ហើយមុន<ពេលឈប់សម្រាក> លោកនិយាយអំពីខ្មាំង ហើយខ្ញុំសួរលោកថាតើខ្មាំងហ្នឹងមានន័យថាយ៉ាងម៉េច។ ឥឡូវនេះខ្ញុំចង់ឲ្យលោក<មានប្រតិកម្ម>ទៅនឹងចម្លើយរបស់សាក្សីមុនលោក ដែលជាប្រធានកងនៅការដ្ឋានហ្នឹង គឺគាត់ធ្វើការនៅក្នុងរយៈពេលតែមួយជាមួយនឹងលោក។ សហព្រះរាជអាជ្ញាសួរសំណួរគាត់ ហើយខ្ញុំនឹងអានសំណួរចម្លើយ គឺនៅកាលពីម្សិលមិញហ្នឹង គឺនៅម៉ោងដប់មួយកន្លះ។ សហព្រះរាជអាជ្ញាបានសួរគាត់ថា៖ "ខ្ញុំចង់ត្រឡប់មកនិយាយអំពីពាក្យ ខ្មាំង។ តើគេចាត់ទុកខ្មាំងហ្នឹង គឺអ្នកដែលរែកដី មិនសម្រេចបានតាមផែនការមែនទេ?"។ ពេលនោះសាក្សីដែលជាមេកងនៅការដ្ឋានដែលមិនមែនមានមុខងារដូចលោកហ្នឹង គាត់បានឆ្លើយថា៖ "បើតាមគេនិយាយនោះ គេចាត់ទុកអ្នកទាំងអស់នោះជាខ្មាំងបង្កប់ ហើយពួកហ្នឹង ហើយដែលជាអ្នកទប់ស្កាត់នូវការរីកចម្រើន"។ អ៊ីចឹងលោកសាក្សី លោកផ្ទាល់ហ្នឹង លោកធ្លាប់ស្តាប់ឮអំពីហេតុផលហ្នឹងទេ ដែលគេថាខ្មាំងហ្នឹងគឺជាអ្នករាំងស្ទះដល់ការរីកចម្រើន?

Deleted: នឹងបន្តិច

Deleted: ឆ្លើយតប

[១០:៤៣:៥៨]

**ឆ៖** ការពិតភាសាខ្មាំងហ្នឹង សំដៅសម្រាប់ខ្ញុំវិញ ខ្ញុំឮថាខ្មាំង ភាសាហ្នឹងខ្មាំងៗអ៊ីចឹងដែរ។ ប៉ុន្តែសំដៅទៅលើខ្មាំងជាប្រភេទណាៗ ខ្ញុំមិនអាចបកស្រាយបានទេ ព្រោះខ្ញុំអត់ដឹង។

**ស៖** លោក ពេលដែលលោកនិយាយថាពីប្រភេទខ្មាំងហ្នឹង លោកចង់មានន័យថាម៉េច?

**ឆ៖** ប្រភេទខ្មាំងហ្នឹង ចង់និយាយថា ដូចសាក្សីមុនគាត់បានច្បាស់ពីរឿងអី អាហ្នឹងជារឿងរបស់គាត់ទេ។ តែសម្រាប់ខ្ញុំអត់ដឹង ថាខ្មាំងហ្នឹងគេសំដៅទៅលើអីៗ គ្រាន់តែដឹងថាខ្មាំងប៉ុណ្ណឹង មិនដឹងគេសំដៅទៅលើអ្នកណា ខ្ញុំអត់ដឹង។

**ស៖** សូមអរគុណសាក្សី។ អ្វីដែលសំខាន់សម្រាប់យើងហ្នឹង គឺចម្លើយរបស់លោកនូវពាក្យនេះ

មិនមែនចម្លើយរបស់សាក្សីមុនទេ។ ខ្ញុំចាប់អារម្មណ៍<ពីអ្វីដែល>លោក<និយាយ> ពីអ្វីដែល<លោកឃើញថា>បានកើតឡើងនៅពេលនោះ។ អ៊ីចឹងលោកសូមជម្រាបនូវតែអ្វីដែលលោកបានដឹងហើយនៅពេលនោះ។ ចំពោះលោក តើមនុស្សពីរនាក់ដែលលោកបាននិយាយពីព្រឹកមិញដែលថា បានបាត់ខ្លួនហ្នឹង តើអ្នកបាត់ខ្លួនហ្នឹងគេចាត់ទុកថា ជាខ្មាំងមែនទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំដឹងតែគាត់បាត់ទៅ មិនថាយ៉ាងម៉េចផង។

**ស៖** អ៊ីចឹងនៅសម័យនោះ តើលោកអាចទាញការសន្និដ្ឋានបានយ៉ាងម៉េចនៅពេលដែលមិត្តភក្តិរបស់លោកពីរនាក់បានបាត់ខ្លួនអ៊ីចឹងនោះ?

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីមិនត្រូវឆ្លើយតប -- មិនចាំបាច់ឆ្លើយតបនឹងសំណួរនេះទេ។ លោកស្រីមេធាវីមិនគប្បីតាំងសំណួរឲ្យសាក្សីផ្តល់សេចក្តីសន្និដ្ឋានទេ ព្រោះគាត់ជាសាក្សី មិនមែនជាអ្នកជំនាញទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមិនទទូចទេលោកប្រធាន ក៏ប៉ុន្តែខ្ញុំគិតថា គឺអង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសួររឿងហេតុដែលបានគាត់ដឹង។ អ៊ីចឹងហើយបានជាខ្ញុំសួរអំពីអ្វីដែលគាត់ដឹង។ <ខ្ញុំគ្រាន់តែចង់សួរពីអារម្មណ៍របស់គាត់ពីអ្វីដែលគាត់បានឆ្លងកាត់កាលនោះ។> អ៊ីចឹងខ្ញុំមិនសួរក៏បាន អាស្រ័យទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ប៉ុន្តែខ្ញុំគិតថាសំណួរនេះគឺវាអាចសួរបាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះលោកឆ្លើយទៅនឹងសហភាគារបស់ខ្ញុំថា កម្មករដែលធ្វើការនៅការដ្ឋានទំនប់ គឺថាមើលទៅដូចជាធម្មតា។ តែនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ លោកឆ្លើយដូចជាផ្សេងពីហ្នឹងទៅវិញ។ ERN ជាភាសាបារាំងគឺ 00422239, ERN ជាភាសាអង់គ្លេស 00403005, ERN ជាភាសាខ្មែរ 00389523។ នៅពេលដែលគេសួរលោកអំពីស្ថានភាពសុខភាពរបស់ប្រជាជននៅទីនោះ លោកបាននិយាយថា៖ "សុខភាពហ្នឹងមិនមានស្រស់ថ្លូរផង់ទេ ប្រជាជនមានសុខភាពទ្រុឌទ្រោម" ហើយបន្ទាប់មកលោកពន្យល់ថា "មានពេទ្យ<នៅកន្លែងហ្នឹងដែរ> ហើយនិងមានកន្លែងគេចែកថ្នាំ"។ អ៊ីចឹងលោកអាចជម្រាបបានទេ អំពីការកត់សម្គាល់របស់លោកនៅសម័យនោះ តើលោកអាចបញ្ជាក់បានទេថា កម្មករហ្នឹងគឺថាមិនមានសុខភាពល្អទេ?

[១០:៤៨:២៨]

Deleted: ត្រង់ចំណុចនេះៗ

Deleted: ព្រោះថា

Deleted: ៗ

Deleted: ដឹង

Deleted: អំ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**លោក ប៊ុច សុខា៖**

**ឆ៖** សំណួរនេះ ខ្ញុំបានជម្រាបពីម្សិលមិញហើយ។ អ្វីដែលខ្ញុំនិយាយថាធម្មតានេះ ឆ្លើយតបនឹងថា មានឃើញហេតុការណ៍អីខ្លះនៅពេលរែកដី ខ្ញុំមើលទៅឃើញធម្មតា ព្រោះអត់មានអីទេ។ តែទាក់ទងអ្វីដែលខ្ញុំបានជម្រាបម្សិលមិញនោះ ខ្ញុំបានជម្រាបរួចហើយ ព្រោះអីពេលដែលអ្នកជំងឺឈឺធ្ងន់គេបញ្ជូនបាត់ទៅ ពេលមានអ្នកឈឺអី។ ដូច្នេះខ្ញុំចាត់ទុកថា អ្នកដែលធ្វើការហ្នឹង គឺជាធម្មតា។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកឃើញថា កាលពី២០០៩ ហ្នឹងលោកឆ្លើយផ្សេង<ពីអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ>។ ពេលនុំងលោកកត់សម្គាល់ឃើញថា សុខភាពប្រជាជនហ្នឹងគឺថា មិនល្អទេ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំលែងសួរហើយ។ ឥឡូវនេះ ខ្ញុំសួរសំណួរចុងក្រោយមួយពាក់ព័ន្ធនឹងបញ្ហាអនាម័យនៅការដ្ឋាន។ សាក្សីមុនលោកនេះ គាត់បាននិយាយថា មានរុយច្រើនណាស់នៅការដ្ឋាន ប្រហែលជាមកពីកង្វះអនាម័យ។ អ៊ីចឹងលោកកត់សម្គាល់ឃើញដូចគាត់ទេនៅសម័យនោះថា មានរុយច្រើនណាស់នៅការដ្ឋាននោះ?

**ឆ៖** បាទ ខ្ញុំឯកភាពនូវអ្វីដែលគាត់បានបង្ហាញហ្នឹង ព្រោះឃើញអ៊ីចឹងដូចគ្នាមែន។

[១០:៥០:១៦]

**ស៖** សាក្សីមុនហ្នឹងគាត់និយាយថា រុយហ្នឹងរំខានមែននៅពេលដែលគេហូបចុកនោះ។ អ៊ីចឹង ខ្ញុំចង់សួរលោក ថាតើរុយនោះពិតជារំខានមែនទេ នៅពេលដែលយើងហូបចុកអ៊ីចឹង ឃើញមានរុយច្រើនទេ បើគិតទៅប្រហែលច្រើនប៉ុនណាដែរ? ខ្ញុំមិនសួរលោកចំនួនប៉ុន្មានឲ្យប្រាកដទេ គ្រាន់តែខ្ញុំចង់ឲ្យលោកនិយាយប្រហាក់ប្រហែលទៅ ព្រោះថាបើសិនជាអានសក្ខីកម្មផ្សេងៗទៅ យើងគិតថា បញ្ហាហ្នឹងវាពិតជាកើតមានមែននៅតាមការដ្ឋានធ្វើការហ្នឹង។ អ៊ីចឹងហើយបានជាខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងចំណុចនេះ។

**ឆ៖** បាទ ទាក់ទងនឹងអារុយនោះវាច្រើនមែនហើយ ប៉ុន្តែគ្រាន់យើងរាប់ថាចំនួនប៉ុណ្ណេះប៉ុណ្ណោះ វាមិនអាចរាប់បានទេ ព្រោះមនុស្សវាច្រើន វាខែប្រាំងផង វាកើតហើយសត្វរុយ វាច្រើន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំសូមបញ្ចប់ត្រឹមនេះ លោកសាក្សី។ ខ្ញុំសូមអរគុណដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ជាដំបូងនេះគឺក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ប៉ិច សុខា។

សូមអញ្ជើញ!

[១០:៥២:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រី ចៅក្រម សូមជម្រាបសួរភាគី សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនមិនជាច្រើនណាស់ណាទេដើម្បីសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាដំបូងខ្ញុំសូមលើកឡើងអំពីអ្វីដែលលោកបាននិយាយកាលពីម្សិលមិញ ពាក់ព័ន្ធនឹងការអប់រំគឺថា លោកបានទៅរៀននៅសាលានៅឫស្សីកែវ ក្នុងទីក្រុងភ្នំពេញ។ កាលពីម្សិលមិញ លោកបាននិយាយថា មានសិស្សប្រហែលជា ១០០នាក់នៅក្នុងថ្នាក់របស់លោក។ ខ្ញុំចង់ដឹងថា តើមុនពេលដែលលោកទៅរៀនដែលមានរយៈពេលប្រាំមួយខែហ្នឹង ថាតើមុនលោករៀនហ្នឹងមានថ្នាក់ផ្សេងទៀត ឬក៏មានឆ្នាំសិក្សាមុនលោកផ្សេងទៀតនៅក្នុងសាលានោះដែរ ឬមួយក៏ថ្នាក់លោកគឺជាថ្នាក់<ដំបូងគេ>នៅក្នុងសាលារៀននោះ?

Deleted: តែមួយទេ

**លោក ប៉ិច សុខា៖**

**ឆ៖** ទាក់ទងនឹងការសិក្សារបស់ខ្ញុំនេះ ខ្ញុំសូមជម្រាបលោកតុលាការថា ពីមុនខ្ញុំទៅរៀន ខ្ញុំក៏មិនបានដឹងថា មានវគ្គមុនខ្ញុំអីទៀត ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែខ្ញុំ ជំនាន់ខ្ញុំទៅរៀន ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេត គឺនៅទំព័រ -- នៅសំណួរទី១ គឺអង់គ្លេសមានលេខ 00403002, ខ្មែរមានលេខ 00389520 និងបារាំងមានលេខ 00422236។ លោកបាននិយាយ ខ្ញុំសូមដកស្រង់៖ "មានផ្នែក<សិក្សា>ជាច្រើន ផ្នែកសាធារណការ ជួសជុលឡាន ម៉ាស៊ីនក្រឡឹង ខាងកសិកម្ម ខាងធារាសាស្ត្រ វារីអគ្គិសនី និងខាងដែក" ហើយលោកបាននិយាយថា "ខ្ញុំមានចំណាប់អារម្មណ៍ខាងធារាសាស្ត្រវារីអគ្គិសនី"។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជានៅពេលនោះលោកចាប់អារម្មណ៍ខាងផ្នែកធារាសាស្ត្រ និងវារីអគ្គិសនី?

**ឆ៖** ទាក់ទងនឹងចំណាប់អារម្មណ៍របស់ខ្ញុំ ខ្ញុំយល់ឃើញថា ពាក្យហ្នឹងវាចម្លែក ខ្ញុំចង់ដឹង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រោះពេលនោះ ខ្ញុំនៅក្មេងដែរ ខ្ញុំមិនដឹងថា ទៅរៀនអី ផលប្រយោជន៍សម្រាប់ផ្ទាល់ខ្លួនអីក៏មាន ប៉ុន្តែឮថាពាក្យហ្នឹងដូចជាចម្លែក ចង់រៀនមើល ដើម្បីអីតែប៉ុណ្ណឹង។

[១០:៥៥:១៦]

**ស៖** ខ្ញុំយល់ ហើយខ្ញុំដឹងថា វាយូរមកហើយ ប៉ុន្តែខ្ញុំចង់ដឹងថា ហេតុអ្វីបានជាផ្នែកធារាសាស្ត្រ វារីអគ្គិសនីហ្នឹងវាគួរឱ្យចាប់អារម្មណ៍ខ្លាំងចំពោះលោកបែបនេះ?

**ឆ៖** ខ្ញុំបកស្រាយ មិនអាចអីពីរឿងដូចខ្ញុំជម្រាបខាងដើម ហៅថា ចំណាប់អារម្មណ៍របស់ខ្ញុំ គឺថាភាសាហ្នឹងវាចម្លែក ព្រោះខ្ញុំមិនដែលឮ។ អីចឹងខ្ញុំចង់រៀនមើល៍ តើវាស្អី? អីចឹងទេ។

**ស៖** តើលោកចាំទេ នៅក្នុងឆ្នាំ៧៦ គឺថាប្រទេសកម្ពុជាហ្នឹងទទួលរងគ្រោះរាំងស្ងួត តើលោកចាំទេ?

**ឆ៖** ខ្ញុំចាំអត់បានទេ លោកតុលាការ។

**ស៖** នៅពេលដែលលោកបញ្ចប់ការសិក្សានៅភ្នំពេញរយៈពេលប្រាំមួយខែ ក្នុងផ្នែកធារាសាស្ត្រ <និង>វារីអគ្គិសនីនោះ តើលោកចាំទេថា លោកពេញចិត្តក្នុងការចាប់ផ្តើមការងារនៅការដ្ឋានទំនប់ក្នុងប្រទេសកម្ពុជា ឬមួយក៏លោកមិនចាំទេ<>?

[១០:៥៧:០២]

**ឆ៖** នៅពេលនោះ គឺសប្បាយចិត្ត មិនសប្បាយចិត្តវាសំខាន់ទេ។ សំខាន់ គឺថាអង្គការគេតម្រូវឱ្យយើងមក យើងត្រូវតែធ្វើតាមអីចឹងហើយ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងលើកបង្ហាញអំពីការងារជាក់ស្តែងនៅទំនប់ តើលោកចាំទេ ថាតើមានការប្រើប្រាស់គ្រឿងចក្រអ្វីទេនៅការដ្ឋានទំនប់នោះ?

**ឆ៖** ខ្ញុំចាំបាន ដោយសារយើងឃើញមានត្រាក់ទ័រឈូសដី មានម៉ៃខូកាយដីអីចឹង មានរបស់គេ។

**ស៖** តើលោកចាំទេ នៅពេលនោះនៅការដ្ឋានហ្នឹង គឺមានត្រាក់ទ័រ មានម៉ាស៊ីនត្រាក់ទ័រឈូសចាយអីប៉ុន្មានគ្រឿងដែរ លោកចាំទេ?

**ឆ៖** អុំ! ដល់ចំនួនគ្រឿងខ្ញុំមិនអាចចាំបានទេ ព្រោះវាមិនមែនការងាររបស់ខ្ញុំគ្រប់គ្រងខាងហ្នឹង។

**ស៖** នៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេត អង់គ្លេសមានលេខ 00403004, បារាំងមានលេខ <004223 8>, ខ្មែរមាន <00389523>។ លោកបាននិយាយថា មានការប្រើប្រាស់ម៉ាស៊ីន

Formatted: Indent: First line: 0.47", No widow/orphan control

Deleted: ¶

Deleted: ថា លោកសប្បាយចិត្ត ឬមិនសប្បាយចិត្តនោះ

Deleted: 232

Deleted: 3

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

គ្រឿងចក្រឈូសឆាយ<ថ្ម> ហើយក្រោយបន្តិចលោកបានបញ្ជាក់ថា គេប្រើប្រាស់រំសេវដើម្បីបំបែកថ្ម។ តើនេះ គឺជាហេតុផល<ត្រឹមត្រូវដែរទេ>ដែលគេប្រើប្រាស់គ្រឿងចក្រ និងរំសេវ<>?

[១០:៥៩:៣៥]

**ឆ៖** រឿងហេតុផលហ្នឹង វាដូចអ្វីដែលខ្ញុំបានជម្រាបពីម្សិលមិញរួចទៅហើយ អត់មានអីក្រៅពីប៉ុណ្ណឹងទៀតទេ។

**ស៖** ប៉ុន្តែវាត្រឹមត្រូវដែរឬទេប្រសិនបើនៅការដ្ឋាននោះ <កន្លែងដែលសុទ្ធតែថ្ម គឺ>គេប្រើប្រាស់គ្រឿងម៉ាស៊ីន< និង>ប្រើប្រាស់រំសេវផ្ទុះដោយគេមិនប្រើប្រាស់<កម្លាំង>មនុស្ស។ តើមានអ៊ីចឹងដែរឬទេ?

**ឆ៖** អាហ្នឹងតាមខ្ញុំជម្រាបម្សិលមិញថា យើងឃើញអ៊ីចឹង តែត្រង់ភាសាថា ត្រឹមត្រូវ មិនត្រឹមត្រូវ ខ្ញុំអត់មានជំនាញខាងហ្នឹងទេ។

**ស៖** ខ្ញុំយល់លោកសាក្សី។ កាលពីម្សិលមិញ លោកបាននិយាយអំពីសហការីរបស់លោកទាំង<បី>នាក់។ តើលោកដឹងទេ ថាតើមានអ្នកបច្ចេកទេស ឬក៏វិស្វករដទៃទៀត ដែលធ្វើការនៅការដ្ឋានទំនប់នោះដែរ?

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹង។

**ស៖** លោកគឺជាអ្នកវាស់ស្ទង់ ហើយក្នុងក្រុមរបស់លោកមានគ្នាបួននាក់ ហើយខ្ញុំសុំហៅលោកថាជាអ្នកបច្ចេកទេស ឬក៏វិស្វករទៅ។ ប៉ុន្តែខ្ញុំចង់ដឹងថា តើមានវិស្វករ ឬក៏អ្នកបច្ចេកទេសផ្សេងទៀតក្រៅពីក្រុមលោក ធ្វើការនៅការដ្ឋានហ្នឹង ដើម្បីត្រួតពិនិត្យទៅលើការងារដែរឬទេ?

[១១:០១:៣៨]

**ឆ៖** ទាក់ទងនឹងព័ត៌មាននេះ ខ្ញុំបានដឹងតែក្រុមខ្ញុំបួននាក់ទេ តែក្រៅពីហ្នឹងទៀត ខ្ញុំអត់ដឹងដែរ។

**ស៖** លោកសាក្សី <លោកបានឆ្លើយមុខចៅក្រមស៊ើបអង្កេត ហើយ>កាលពីម្សិលមិញលោកក៏បាននិយាយប្រាប់ថា ប្រជាជនដែលធ្វើការនៅការដ្ឋាននោះ ត្រូវបានគេណែនាំឲ្យ<ម្នាក់>រែកដីប្រហែលជា២ម៉ែត្រគូប។ តើលោកដឹងទេថា តើគេប្រើប្រាស់ការគណនាបែបណា<នៅពេលនោះ>ដើម្បីកំណត់ថា មនុស្សម្នាក់ហ្នឹងអាចរែកដីបានប្រហែលជា២ម៉ែត្រគូបនោះ?

**ឆ៖** ការងារនេះ ខ្ញុំដឹងតាមការចាក់មីក្រូ តែរឿងការលម្អិត រឿងថាវាស់ដីបាន២ម៉ែត្រគូបបានមិនបាន អាហ្នឹងមិនមែនជាការងារខ្ញុំទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Deleted:** ជីកទំនប់ប្រឡាយ

**Deleted:** មែនទេ

**Deleted:** ដែលថា

**Deleted:** មាន

**Deleted:**

**Deleted:** ដើម្បីធ្វើការងារ ឬក៏គេ

**Deleted:** ពីរ

**ស៖** ប៉ុន្តែតើលោកមានការដឹង ឬក៏បទពិសោធន៍អ្វី<ពី>ការសិក្សា<នៅភ្នំពេញ> ដែលថាគេតម្រូវ<ម្នាក់>ឲ្យរែក២ម៉ែត្រគូប ហេតុអ្វីក៏មិន១,៥ម៉ែត្រគូប ឬក៏២,៥ម៉ែត្រគូបអ៊ីចឹងទៅ? ហេតុអីបានជាគេកំណត់ឲ្យរែកតែ២ម៉ែត្រគូបក្នុងមនុស្សម្នាក់នោះ?

[១១:០៣:៤៦]

**ឆ៖** ទាក់ទងសំណួរនេះ ខ្ញុំមិនអាចឆ្លើយបាន ព្រោះខ្ញុំអត់ដឹងដែរ។

**ស៖** ផ្អែកទៅលើការដែលលោករៀនសូត្រ ក៏ដូចជាការជជែកគ្នាជាមួយអ្នកធ្វើការជាមួយនោះ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាគេត្រូវការកម្មករ -- ហេតុអ្វីបានជាកម្មករដែលជាអ្នកធ្វើហ្នឹង មានចំនួន<ប្រហាក់ប្រហែល>ដល់ទៅ២០.០០០នាក់? ហេតុអ្វីក៏មិនយក២៥.០០០ ឬក៏១៥.០០០? តើលោកអាចបញ្ជាក់បានទេថា ហេតុអ្វីដែរ?

**ឆ៖** ការងារនេះ ខ្ញុំអត់ដឹងទេ ព្រោះអីខ្ញុំឮតែតាមប្រកាសមីក្រូ តែរឿងហេតុផល រឿងអី ខ្ញុំអត់យល់ ហើយក៏មិនដឹងដែរ។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយ។ ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនទៀត ទាក់ទងទៅនឹងស្ថានភាពការងារនៅការដ្ឋានទំនប់នោះ។ ខ្ញុំបានកត់ត្រានូវចម្លើយមួយចំនួនដែលលោកបានឆ្លើយកាលពីម្សិលមិញ ក៏ដូចជានៅចំពោះសហចៅក្រមស៊ើបអង្កេត។ លោកបាននិយាយថា កម្មករភាគច្រើនធ្វើការនៅពេលព្រឹក <និងពេលថ្ងៃ> ហើយមានម្តងម្កាល គឺថាពួកគេត្រូវបានស្នើឲ្យធ្វើឲ្យខ្លាំងក្លាជាងមុន។ ហើយនៅចំពោះមុខអ្នកស៊ើបអង្កេត គឺលោកនិយាយថា ពួកគេអាចសម្រាកមុន ប្រសិនគេជីកដីរែកដីបានចប់សព្វគ្រប់។ ហើយនៅក្នុងពេលថ្ងៃ គេមានពេលឈប់សម្រាកប្រហែលជា១៥នាទីម្តង។ ដូច្នេះ តើខ្ញុំអាចនិយាយបានទេ គឺថាខ្ញុំសង្ខេបទៅលើអ្វីដែលលោកបាននិយាយទាក់ទងទៅនឹងពេលវេលា<និងលក្ខខណ្ឌការងារ> តើខ្ញុំនិយាយបែបនេះ វាជាការសមស្របទេ?

[១១:០៦:០៦]

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹង។

**ស៖** ខ្ញុំទើបតែបានដកស្រង់នូវចម្លើយរបស់លោកមួយចំនួន ដែលបានលោកបានឆ្លើយកាលពីម្សិលមិញ ក៏ដូចជានៅជាមួយសហចៅក្រមស៊ើបអង្កេត។ ហើយសំណួរខ្ញុំ គឺខ្ញុំចង់សួរថា អ្វីដែលខ្ញុំសង្ខេបទៅលើចម្លើយរបស់លោកទាក់ទងទៅនឹងម៉ោងពេលធ្វើការងារ<នៅការដ្ឋាន>ហ្នឹង គឺវាត្រឹមត្រូវ<ឬក៏អត់>។ ឥឡូវខ្ញុំ<រឹករាយរៀបសំណួរ>ឡើងវិញ គឺថាលោកនិយាយថា ពួកគេធ្វើការតែ<>

Deleted: ទាក់ទងនឹង

Deleted: តែ

Deleted: នឹងបញ្ជាក់លោក

ថ្ងៃប៉ុណ្ណោះ ហើយពេលខ្លះ គេស្នើឲ្យប្រជាជនហ្នឹងខំប្រឹងធ្វើការជាងមុន។ ពួកគេអាចឈប់សម្រាកនៅពេលដែលពួកគេជីកដី រែកដី<រួចមុន>។ ហើយនៅក្នុងពេលធ្វើការពេលថ្ងៃពេលព្រឹកហ្នឹង ពួកគេអាចឈប់សម្រាកបានប្រហែល១៥នាទី។ អ៊ីចឹង ខ្ញុំនិយាយសង្ខេបទៅលើការងារហ្នឹង ត្រឹមត្រូវដែរឬទេ?

[១១:០៧:០៣]

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន មុនពេលដែលសាក្សីឆ្លើយ ខ្ញុំមិនយល់ថា តើវាមានប្រយោជន៍អ្វីដែលមេធាវីគាត់សង្ខេបទៅលើចម្លើយនោះ។ <លោកមេធាវីមានបំណងសង្ខេបភស្តុតាងដែលគាត់ដកចេញពី>កំណត់ត្រា <តែ>នេះមិនមែនជាការដកស្រង់<តាមន័យត្រង់នោះ>ទេ <ឃ្លាទាំងនេះត្រូវបានរៀបឡើងសាជាថ្មី>។ <>ភស្តុតាងវាមាននៅក្នុងសំណុំរឿងរួចទៅហើយ ដូច្នេះ មិនចាំបាច់ត្រូវលើកយកមកនិយាយឡើងវិញនោះឡើយ។ ហេតុអ្វីចាំបាច់ត្រូវសង្ខេបទៅលើចម្លើយរបស់សាក្សីធ្វើអី ប្រសិនបើយើងមាន<សក្ខីកម្ម>សាក្សីនៅទីនេះរួចទៅហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំគួរតែមានសិទ្ធិ គួរតែសួរទៅលើអ្វីដែលខ្ញុំអាចសួរបាន ហើយ<សម្រង់ទាំងប្អូនដែល>ខ្ញុំបានដកស្រង់<គឺជាសម្រង់ផ្ទាល់ពីសក្ខីកម្មសាក្សី និង>កំណត់ហេតុស្តាប់ចម្លើយរបស់គាត់<>។ <អ៊ីចឹង ខ្ញុំគិតថា> ខ្ញុំអាចសួរថា អ្វីដែលខ្ញុំសង្ខេបហ្នឹងគឺជាការសង្ខេបត្រឹមត្រូវ ឬក៏ជាអ្វីដែលគាត់និយាយបានត្រឹមត្រូវ<ពីពេលវេលាធ្វើការដែរឬទេ>។ ដូច្នេះ ខ្ញុំមានសិទ្ធិក្នុងការសួរ។

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ប្រសិនបើជាការដកស្រង់<ន័យត្រង់> វា<រឹតតែគ្មានប្រយោជន៍ទៅទៀតហើយព្រោះ>សំខាន់ភស្តុតាង គឺមាននៅក្នុងសំណុំរឿងរួចទៅហើយ។ <គាត់តាមពិតទៅកំពុងតែសួរសាក្សីថាតើអ្វីជាភស្តុតាងនៅក្នុងសំណុំរឿងហ្នឹងហើយ។> ហេតុដូច្នេះវាមិនចាំបាច់ត្រូវយកមកដកស្រង់ទេ។ ហើយម្យ៉ាងទៀត <បើ>ការដកស្រង់នេះ ជាការដកស្រង់ដោយមិនត្រឹមត្រូវ វាធ្វើឲ្យ<មានភាពផ្ទុយគ្នា>។

[១១:០៨:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១០:១៨]

**Deleted:** ព្រឹក ហើយនិង

**Deleted:** ហើយ

**Deleted:** ប៉ុន្តែដើម្បីជា

**Deleted:** គឺខ្ញុំសូមនិយាយថា

**Deleted:** ត្រឹមត្រូវ

**Deleted:** ផ្ទាល់

**Deleted:** ព្រោះ

**Deleted:** ថា

**Formatted:** Indent: First line: 0.47", No widow/orphan control

**Deleted:** ទៅអ្វី¶
ដែលបាននិយាយរួចមកហើយ។
ហើយ

**Deleted:** ក៏ដូចគ្នាដែរ

**Deleted:** តិចទេ

**Deleted:** មិនមានបញ្ហាអ្វីទេ ប៉ុន្តែ

**Deleted:** ហើយដោយសារតែមានភស្តុតាង មានសាក្សី

**Deleted:** ជាការនាំមុខ

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី មុនពេលដែលយើងធ្វើការសម្រេចថាតើគោលៗបំណងនៃការសង្ខេបរបស់លោកហ្នឹង គឺជាការបង្កើតមូលដ្ឋានសម្រាប់ការសួរ<សំណួរពាក់ព័ន្ធ>តទៅមុខទៀត ឬក៏គ្រាន់តែសង្ខេបដើម្បីតែការសង្ខេបប៉ុណ្ណោះ?

Deleted: បន្ថែម

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបន្តទៅមុខទៀតលោកចៅក្រម ប្រសិនបើដូច្នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <លោកសាក្សី> ខ្ញុំចង់សួរលោកសំណួរជាក់លាក់មួយទាក់ទងទៅនឹងពេលវេលាបំពេញការងារ។ នៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេត អង់គ្លេស 00403006, បារាំង 00422241 និងខ្មែរ 00389524។ លោកបាននិយាយថាពេលបំពេញការងារនៅការដ្ឋាន<ទំនប់>នោះ គឺចាប់ពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយពីពេលព្រឹក និងពេលរសៀល ពីម៉ោងពីរដល់ម៉ោងប្រាំ។ ក្នុងចន្លោះម៉ោងធ្វើការ <លោកប្រាប់ថា> គេឲ្យឈប់សម្រាក១៥នាទី ហើយពេលយប់ ធ្វើពីម៉ោងប្រាំមួយសាមសិប ដល់ម៉ោងដប់។ <ខ្ញុំនឹងសួរពីការងារយប់នៅពេលក្រោយទៀត តែ>ឥឡូវនេះខ្ញុំមានសំណួរមួយ ចង់ដឹងថាហេតុអ្វីចន្លោះពីម៉ោងដប់មួយដល់ម៉ោងពីររសៀលហ្នឹងកម្មករ គេអត់ធ្វើការនៅការដ្ឋាន?

[១១:១២:០៤]

**លោក ប៊ិច សុខា៖**

**ឆ៖** អាហ្នឹង រឿងហេតុអីខ្ញុំមិនដឹងដែរ ប៉ុនអាហ្នឹងគេម៉ោងគេឲ្យសម្រាកអីចឹង។

**ស៖** តើលោកដឹងថាពេលឈប់សម្រាក៣ម៉ោងនេះ គឺនៅក្នុងចន្លោះម៉ោងដប់មួយ ដល់ម៉ោងពីររសៀលហ្នឹង គឺដោយសារតែពេលហ្នឹងជាពេលថ្ងៃត្រង់ក្ដៅខ្លាំង តើមែនទេ?

**ឆ៖** បាទ ការពិតវាថ្ងៃក្ដៅហើយម៉ោងប៉ុណ្ណឹង។

**ស៖** នៅពេលនោះ តើលោកធ្លាប់ឮទេថា ហេតុផលដែលគេអនុញ្ញាតឲ្យ -- តើមានហេតុផលអ្វីដែលគេអនុញ្ញាតឲ្យកម្មករ២០.០០០នាក់ហ្នឹង គាត់ឈប់សម្រាកពេលបីម៉ោង នៅពេលថ្ងៃហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹងដែរ ខ្ញុំដឹងតែប៉ុណ្ណឹង គេឲ្យសម្រាក ប៉ុណ្ណឹង។

**ស៖** ពេលឈប់សម្រាក១៥នាទីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុរបស់លោកហ្នឹង តើគេឲ្យឈប់សម្រាក១៥នាទីជារៀងរាល់ថ្ងៃក្នុងពេលប្រហែលៗគ្នា <ហើយបើអីចឹង តើគេប្រកាសក្នុង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការដ្ឋានទាំងមូលនៅពេលនោះទេ?> តើលោកចាំ<អ្វីបានខ្លះ>អាពេលឈប់សម្រាក១៥នាទីក្នុងពេលធ្វើការហ្នឹង <>?

Deleted: ឬក៏នៅពេលដែលគេបញ្ចប់ការងារនូវអ្វីដែលធ្វើនោះ?

Deleted: ទេ ថាតើ

Deleted: គេឈប់សម្រាកលក្ខណៈបែបណាដែរ

**ឆ៖** ខ្ញុំចាំបានថាចន្លោះនៃព្រឹក និងល្ងាចនៅចន្លោះកណ្តាលនីមួយៗ គេឲ្យសម្រាកអ៊ីចឹងជាធម្មតា។

[១១:១៤:១៤]

**សៈ** តើលោកចាំទេ ថាគេប្រកាសជាទូទៅតាមរយៈឧគ្ឃោសនសព្ទប្រាប់ដល់កម្មករទាំងអស់ឲ្យឈប់សម្រាក១៥នាទីនៅក្នុងពេលបំពេញការងារហ្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ ពេលសម្រាកហ្នឹង គេប្រកាសមេក្រូតាមការដ្ឋានហ្នឹង ម៉ោងសម្រាកគេឲ្យសម្រាក ម៉ោងធ្វើការគេឲ្យធ្វើការ។

**សៈ** តើគេៗប្រកាសអាពេលឈប់សម្រាកបីម៉ោងក្នុងពេលបាយថ្ងៃត្រង់ហ្នឹង ក៏គេប្រកាសតាមមីក្រូដែរឬទេ? ខ្ញុំចង់និយាយថា ពេលដែលគេឲ្យឈប់សម្រាក ពេលចាប់ផ្តើមឈប់សម្រាកហ្នឹងគេប្រកាសជាទូទៅតាមមីក្រូអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**សៈ** តើលោកធ្លាប់ឃើញគេមានអ្នកគេបញ្ជាឲ្យពលករ កម្មករហ្នឹងធ្វើការក្នុងរយៈពេលឈប់សម្រាកបីម៉ោង ឬក៏ក្នុងរយៈពេលឈប់សម្រាក១៥នាទីហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានតាមដានទេ ការងារហ្នឹង បាទ។

**សៈ** ឥឡូវនេះ ខ្ញុំនិយាយអំពីការធ្វើការនៅពេលយប់វិញម្តង។ ខ្ញុំមានសំណួរ<បន្ត>មួយចំនួន<លើចំណុចនេះ។> លោកនិយាយថាកម្មករធ្វើការនៅពេលយប់ផងដែរ។ បើតាមខ្ញុំចាំគឺថាមិនមែនទៀងទាត់ និងមិនមែនជារៀងរាល់ថ្ងៃនោះទេ។ តាមការសង្កេតរបស់លោក តើលោកមានឮការប្រកាសដូចជាការប្រកាសនៅក្នុងទស្សនាវដ្តីទង់បដិវត្តឆ្នាំ៧៧ ដែលនិយាយអំពីប្រយោជន៍ <និងផលប៉ះពាល់> នៃការធ្វើការងារនៅពេលយប់ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលដឹងទេ លោកតុលាការ បញ្ហាហ្នឹង។

[១១:១៦:៥៥]

**សៈ** លោកសាក្សី ខ្ញុំសូមអាននូវសម្រង់ខ្លីមួយចេញពីទស្សនាវដ្តីទង់បដិវត្តឲ្យលោកស្តាប់។ លោកប្រធាន គឺឯកសារ E3/170, អង់គ្លេស 00182578, បារាំងមានលេខ 00665429 និងខ្មែរមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លេខ 00064792។ ក្នុងទំព័រនៃទស្សនាវដ្តីទង់បដិវត្តមួយនេះ ខ្ញុំសូមអានដូចតទៅនេះ៖ "ក្នុងពេលកន្លងមកយើងបានពិសោធថា ផលប្រយោជន៍នៃការធ្វើការនៅពេលយប់គឺវាមានតិច ប៉ុន្តែ<ការខាតបង់ក៏មាន>ច្រើន<ដែរ>។ ទី១ គឺផលប៉ះពាល់ទៅលើសុខភាព, ទី២ គឺការចំណាយទៅលើអគ្គិសនី និងទី៣<ការខាតបង់ដ៏ធំនោះ>គឺ ខាងសតិអារម្មណ៍ <និង>នយោបាយ។" តើនៅពេលដែល -- នៅពេលនោះតើលោកមានធ្លាប់ឮមេរបស់លោក <ឬអ្នកដទៃទៀត>និយាយអំពីផលប៉ះពាល់ ឬក៏ការខាតបង់ដែលធ្វើការនៅពេលយប់<បើយោងតាមទស្សនាវដ្តីទង់បដិវត្ត ឬបក្សកុម្មុយនីស្តកម្ពុជា>ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលឮផង។

**ស៖** ចុះចំពោះបញ្ហាអគ្គិសនីនៅការដ្ឋានទំនប់នោះវិញ តើលោកចាំទេថា នៅពេលយប់គេមានភ្លើងអគ្គិសនីអ្វីបំភ្លឺដែរឬទេ នៅការដ្ឋាននោះ?

**ឆ៖** ខ្ញុំចាំបានថាពេលយប់គេមានភ្លើងបំភ្លឺដែរ តាមការដ្ឋាន ប៉ុន្តែត្រង់ថាវាថេរ ឬក៏មិនថេរខ្ញុំចាំមិនបានទេ។

[១១:១៩:២១]

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំមានសំណួរមួយចុងក្រោយទាក់ទងទៅនឹង<កម្លាំង>ការងារ តើលោកដឹងទេនៅក្នុងក្រុមមនុស្ស ២០.០០០នាក់នោះ គឺមានការផ្លាស់ប្តូរកម្លាំងពលកម្ម គឺថាមានពលករថ្មីមកជំនួស ពលករចាស់។ ដូច្នេះ គឺក្នុងចំណោមកម្លាំងពលកម្មដែលធ្វើការ<ក្នុងរយៈពេលប្រាំមួយខែ ឬយូរជាងនេះ> ២០.០០០នាក់ហ្នឹង គឺថាកម្មករទាំងអស់ មិនមែនជាកម្មករដដែលៗទេ គឺគេមានការប្តូរវេនគ្នា តើលោកចាំពីចំណុចនេះទេ?

**ឆ៖** ទាក់ទងនឹងសំណួរនេះ ខ្ញុំឆ្លើយអត់បានទេ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបៗ! លោក ប៉ិច សុខា កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ នាងខ្ញុំសូមធ្វើការជំទាស់ទៅនឹងសំណួរនេះ ពីព្រោះថាលោក វ៉ិចទ័រ កូប៉េ គាត់បានលើកតាំងសំណួរសួរទាក់ទងទៅនឹងចំនួនកម្មករ២០.០០០នាក់ជាង ដែលកម្មករបានបង្ហាញតាំងពីព្រឹករហូត -- កាលពីម្សិលមិញក៏ដូចជាតាំងពីព្រឹកមិញ។ រាល់ការងារក្រៅពីការងាររបស់

Deleted: ចំណាយទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់ គឺគាត់មិនបានដឹងឮទេ។ ហើយដូច្នេះហើយសូមឲ្យលោក កូប៉េ ហ្នឹងរៀបចំសំណួរសាឡើងវិញ ពីព្រោះសាក្សីក៏ពុំសមត្ថភាពនៅក្នុងការដឹងទៅលើការងាររបស់កម្មករដល់ទៅចំនួន ២០.០០០នាក់ជាង នេះដែរ។ អ៊ីចឹងសូមជំទាស់ទៅលើសំណួរនេះ។ សូមអរគុណលោកប្រធាន។

[១១:២១:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា យើងមិនជំទាស់ទេថាមានកម្មករប្រហែល២០.០០០នាក់ ហើយសាក្សីហ្នឹងក៏បាននិយាយរួចទៅហើយអំពីចំនួនកម្មករប្រហែល២០.០០០នាក់<នេះដែរ>។ ដូច្នេះ ខ្ញុំ<គិតថា ខ្ញុំអាចសួរសំណួរនេះបាន>។

Deleted: មិនយល់ថាហេតុអ្វីខ្ញុំមិនអាចសួរអំពីកម្មករ២០.០០០នាក់នោះបាន

**ប្រធានអង្គជំនុំ៖**

បាទ បដិសេធនូវសេចក្ដីជំទាស់។ មេធាវីអាចសួរបាន។ ដោយសារអ៊ីចេះ គាត់ សាក្សីគាត់ជាការងាររបស់គាត់ គឺដើរធ្វើការងារពីចុងទំនប់ទៅដើមទំនប់។ អ៊ីចឹងអ្វីដែលគាត់អាចសង្កេតគឺគាត់អាចធ្វើការសង្កេតបាននូវបទពិសោធន៍ដែលគាត់ធ្វើការងារ។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្ដីអម្បាញ់មិញនេះ!

[១១:២២:០២]

**លោក ប៉ិច សុខា៖**

**ឆ៖** បាទ លោកប្រធាន ការងារការផ្លាស់ប្ដូរអីហ្នឹង ខ្ញុំក្លាប់អត់បានដែរទេ ព្រោះខ្ញុំអត់ចូលក្នុងការងារហ្នឹងទេបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរបន្តអំពីស្ថានភាពសុខភាព ស្ថានភាពសុខាភិបាលក៏ដូចជា ពិសេសគឺអំពីខ្លួនលោកផ្ទាល់។ តើនៅពេលដែលលោកនៅធ្វើការនៅការដ្ឋានហ្នឹង តើលោកធ្លាប់ជួបប្រទះ ឬក៏ធ្លាប់មានជំងឺ ឧទាហរណ៍ដូចជាជំងឺរាក ឬក៏គ្រុនជាដើមនោះ។ ថាតើ -- ប្រសិនបើលោកធ្លាប់ឈឺ តើលោក<ទាមទៅចាំថាបាន>ទទួលបានការព្យាបាល ឬក៏ទទួលបានជាឱសថ ជាថ្នាំពេទ្យអ្វីដែរឬទេ? <ហើយបន្ទាប់មក ជំងឺលោកហ្នឹងព្យាបាលជាទេ?>

Deleted: តើ

**ឆ៖** សម្រាប់ផ្ទាល់ខ្លួនខ្ញុំមានការឈឺគ្រុនបន្តិចបន្តួចដែរ ប៉ុន្តែគ្រាន់ពេលឈឺគ្រុន គឺបានថ្នាំលេបអ៊ីចឹងដែរ ព្រោះអីខ្ញុំមិនដែលឈឺធ្ងន់ផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01502163



[១១:២៣:១៩]

**ស៖** នៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេតទៅលើបញ្ហានេះគឺERN <00403004> ជាភាសាអង់គ្លេស, បារាំង 00422240 <-- 39 ទេសុំទោស> និងខ្មែរមានលេខ 00389523។ លោកបាននិយាយថា ឱសថដែលគេផ្តល់ឲ្យលោកហ្នឹងគឺមានប្រសិទ្ធភាព។ គឺថាថ្នាំដែលផ្តល់ឲ្យលោកហ្នឹងគឺមានប្រសិទ្ធភាព<សម្រាប់លោក>។ តើ<លោកមានបានសង្កេតឃើញថា>ចំពោះប្រជាជនដទៃទៀតដែលឈឺហ្នឹង នៅពេលដែលគេឲ្យថ្នាំលេបហ្នឹង តើលេបទៅជាដែរឬក៏អត់? ហើយថាតើថ្នាំដែលឲ្យប្រជាជនផ្សេងទៀតហ្នឹង គឺមានប្រសិទ្ធភាពដែរឬអត់?

**ឆ៖** ខ្ញុំអត់ដឹងទេ ការងារហ្នឹង ព្រោះខ្ញុំអត់មានទាក់ទងនឹងការងារផ្នែកពេទ្យនៅពេលនោះ។

**ស៖** មិនអីទេលោកសាក្សី ខ្ញុំ<មិនមានសំណួរអីទៀតទេ> សំណួរដែលខ្ញុំចង់សួរជាចុងក្រោយនេះគឺថា តើលោកធ្លាប់ឃើញការរៀបអាពាហ៍ពិពាហ៍<ច្រើនគូ>ដែលគេធ្វើឡើងនៅទំនប់១មករាហ្នឹងដែរឬទេ?

**ឆ៖** សម្រាប់ខ្ញុំផ្ទាល់អត់ដែលបានឃើញទេ លោកតុលាការ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី លោកបានជួយខ្ញុំច្រើន ហើយខ្ញុំសូមអរគុណ ហើយសូមបញ្ចប់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១១:២៥:២៧]

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន។ សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ប៊ិច សុខា! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ហើយខ្ញុំសូមចោទសំណួរខ្លីៗទេ បន្តពីអ្វីដែលលោកបានរៀបរាប់រយៈពេលពីរថ្ងៃកន្លងមកនេះ។ ជាដំបូង មានចំណុចមួយនៅក្នុងចម្លើយរបស់លោក<នៅចំពោះមុខអ្នកស៊ើបអង្កេត> គឺឯកសារ E3/403, ERN ជាភាសាបារាំងគឺ 00422238, អង់គ្លេសគឺ 00403004, ជាភាសាខ្មែរគឺ

Deleted: 6

Deleted: មានសំណួរតិចតួចទេនៅសល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<00389522>។ ទាក់ទងទៅនឹង ប្លង់ទំនប់ គេសួរថា៖ “តើ<លោកគិតថា>ផែនការធ្វើ<ទំនប់នេះ បើតាមការវាស់ស្ទង់របស់លោក> តើវាត្រូវនឹងបទដ្ឋានដែរឬទេ?” ចម្លើយរបស់លោកគឺថា៖ “ខ្ញុំគិតថាប្លង់នេះមានមូលដ្ឋានច្បាស់លាស់ព្រោះថា បើយើងមើលពីលើមក យើងនឹងឃើញខ្សែហ្នឹងសមស្របនឹងបទដ្ឋាន។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួររបស់ខ្ញុំលើចំណុចនេះ លោកសាក្សី គឺខ្ញុំចង់ដឹងថាតើលោកបានរៀនអានប្លង់ហ្នឹងនៅក្នុង<វគ្គ>បណ្តុះបណ្តាលនៅឫស្សីកែវដែរឬទេ?

**លោក ប៉ិច សុខា៖**

**ឆ៖** ទាក់ទងនឹងខ្ញុំផ្ទាល់ការងារប្លង់ការងារផ្នែកធារាសាស្ត្រ វារីអគ្គិសនីនេះ កម្រិតខ្ញុំរៀននៅសាលាឫស្សីកែវនេះ គឺឃើញថាត្រូវហើយ។

[១១:២៧:៤១]

**ស៖** ខ្ញុំ<ពិតជា>យល់<ចំណុចហ្នឹង>ហើយ ក៏ប៉ុន្តែសំណួររបស់ខ្ញុំគឺថា នៅក្នុងពេលដែលលោករៀនសូត្រនៅឫស្សីកែវនោះ លោកមានបានរៀនពីប្លង់ប្រព័ន្ធស្រោចស្រពទេ?

**ឆ៖** រៀននៅសាលាឫស្សីកែវនេះ គេបង្រៀនអំពីការស្ទង់ដី ស្ទង់ទំនប់ ស្ទង់ប្រឡាយ។ ឯរឿងអី ស្រោចស្រពអីផ្សេងទៀតគឺមិនបានរៀនទេ។

**ស៖** នៅក្នុងក្របខ័ណ្ឌទទួលការបណ្តុះបណ្តាលធ្វើជាអ្នកវាស់ស្ទង់ហ្នឹង តើលោកមានបានរៀន<អាន>ប្លង់ស្រោចស្រពដែរឬទេ?

**ឆ៖** អត់បានរៀនផង។

**ស៖** តើគ្រូបង្រៀនរបស់លោកឈ្មោះ ឆាំ ហ្នឹងហើយដែលលោកបានពិភាក្សាជាមួយគាត់ ហើយដែលគាត់និយាយថា សមស្របនឹងបទដ្ឋាន ត្រឹមត្រូវតាមបទដ្ឋាន អ៊ីចឹងមែនទេ?

**ឆ៖** ឆាំ ហ្នឹងគាត់មិនមែនគ្រូទេ គាត់ជាមេក្រុមខ្ញុំ។ ហើយគាត់អ្នកចេះដឹងជាងខ្ញុំ ពេលនោះខ្ញុំក្មេង ក្មេងបំផុតហើយ។ ដូច្នេះគាត់ថាធ្វើហ្នឹងវាសមស្របប្លង់ហ្នឹង យើងធ្វើតាមប្លង់ហ្នឹងត្រូវហើយ។ គាត់និយាយអ៊ីចឹង។

[១១:២៩:៣៧]

**ស៖** ចំណុចមួយទៀត លោកបាននិយាយពីចំណុចមួយជាមួយលោកមេធាវី កូប៉េ នៅក្នុងចម្លើយ -- កំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ។ <ខ្ញុំចង់ត្រឡប់ទៅចំណុចហ្នឹងវិញ ហើយចង់ស្វែងយល់លំអិតជាងមុន> គឺនៅទំព័រដដែល គឺថាលេខ ERN ដែលខ្ញុំបានរៀបរាប់អម្បាញ់មិញហ្នឹង។

Deleted: 5

Deleted: ទំនប់នេះមាន

Deleted: រយៈពេលប៉ុន្មានដែរ --

Deleted: ការទទួលការ

Deleted: ពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកបាននិយាយអំពីការប្រើប្រាស់អេស្កាវ៉ាទ័រ ម៉ាស៊ីនផ្សេងៗ លោកបាននិយាយដូច្នេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឮតាមមីក្រូ ដោយគេប្រកាសទៅជនរួមជាតិទាំងអស់ឲ្យប្រយ័ត្នប្រយែង ពីព្រោះគេនឹងប្រើគ្រឿងបំផ្ទុះៗ ដើម្បីយកថ្មចេញ"។ សូមបញ្ចប់ការដកស្រង់។ តើការប្រកាសឲ្យប្រយ័ត្នប្រយែងនេះគេប្រកាសជាញឹកញាប់ដែរឬទេ តាមមីក្រូនៅការដ្ឋានហ្នឹង?

**ឆ៖** បាទ រៀងរាល់ពេលដែលចុចរំសេវផ្ទុះ គេប្រកាសអ៊ីចឹងហើយ ដើម្បីកុំឲ្យមានគ្រោះថ្នាក់អី។

**ស៖** ក្រៅពីការប្រកាសឲ្យប្រយ័ត្នប្រយែង<សុវត្ថិភាព>ហ្នឹង តើមានការប្រកាសទាក់ទងទៅនឹងអនាម័យដែរឬទេ សម្រាប់អ្នកធ្វើការនៅលើការដ្ឋានហ្នឹង?

**ឆ៖** អាហ្នឹង ខ្ញុំដូចចាំអត់បានទេ លោកតុលាការ។

[១១:៣១:១៤]

**ស៖** តើលោកចាំ ថាតើគ្រូពេទ្យបានចេញវេជ្ជបញ្ជាច្បាស់លាស់តាមមីក្រូ ឬក៏តាមមេលោកផ្ទាល់ ឬក៏តាមវិធីណាផ្សេង មានផ្តល់ជាអនុសាសន៍ ឬការណែនាំអីផ្នែកអនាម័យដែរឬទេ? ឬក៏ត្រូវអនុវត្តយ៉ាងម៉េចទាក់ទងនឹងអនាម័យនេះ មានធ្លាប់ទទួលការណែនាំបែបហ្នឹងទេ?

**ឆ៖** ខ្ញុំដូចចាំអត់បានទេ ត្រង់ហ្នឹង។

**ស៖** លោកបាននិយាយថា មានរុយច្រើន និយាយទៅកាន់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើមានការចាត់វិធានការណាមួយនៅលើការដ្ឋាននេះ ដើម្បីបណ្តេញរុយឲ្យអស់ឧទាហរណ៍ដូចជា ប្រើថ្នាំបាញ់មូស ឬបាញ់រុយ អីជាដើមនោះ មានចាត់វិធានការបែបហ្នឹងទេ? លោកចាំទេ?

**ឆ៖** បាទ ត្រង់ហ្នឹង ខ្ញុំឃើញពេលដែលរុយច្រើន មានពេទ្យគេមកបាញ់ថ្នាំសម្លាប់រុយ។ ឃើញគេធ្វើដែរ។

**ស៖** តើលោកដឹងថា អ្នកណាជាអ្នកទទួលបន្ទុកខាងបាញ់ថ្នាំមូសហ្នឹងទេ ឬក៏មានផ្នែកណាជាក់លាក់ ឬពិសេសណាមួយ <ឬក៏>លោកមិនដឹង<ទេ>?

**Deleted:** ហើយដែល

**ឆ៖** ត្រង់ចំណុចនេះ ខ្ញុំអត់ដឹងដែរ មិនអាចឆ្លើយបានព្រោះអត់ដឹង។

[១១:៣៣:២៤]

**ស៖** ផ្នែកមួយនៃចម្លើយរបស់លោកដដែល គឺនៅឯកសារដដែលគឺនៅ <E3/403> ជាភាសា

**Deleted:** 304

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បារាំង ERN <00422243>, ERN ជាភាសាអង់គ្លេសគឺ 00403008 ជាភាសាខ្មែរគឺ 00389527។ លោកនិយាយពីពាក្យ*ស្លូហ្គង់*មួយ ពាក្យស្លោកមួយដែលថា "មានទឹកមានត្រី មានស្រូវអ្វីៗក៏មានដែរ"។ តើលោកចាំថា លោកបានឮពាក្យស្លោកហ្នឹងនៅពេលណាដែរឬទេ? ឬ ហើយជាពាក្យស្លោកដែលគេតែងតែប្រកាសរហូតនៅលើការដ្ឋានហ្នឹងពេលដែលគេលើកទំនប់ហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំឮតាមមីក្រូប្រកាសហ្នឹងឯង ហើយចម្រៀងបដិវត្តន៍ពេលនោះក៏មានដែរ។ ខ្ញុំជឿថាប្រជាជននៅជំនាន់នុំងគេអាចឮដូចខ្ញុំអ៊ីចឹងដែរ។

**សៈ** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ និយាយថា "កាលណាមានទឹកមានត្រី" តើគឺជាពាក្យស្លោកដែលលោកទើបឮលើកទី១ ហើយនៅលើការដ្ឋានហ្នឹង ឬក៏ជាសុភាសិតដែលមានតាំងពីដូនតាមកហើយ តាំងពីមុនរបបខ្មែរក្រហមទៀត ឬក៏យ៉ាងណា?

[១១:៣៥:០០]

**ឆ៖** ខ្ញុំអត់ដែលដឹងទេពីមុនមក ខ្ញុំដឹងនៅពេលដែលខ្ញុំឮនៅពេលខ្ញុំធ្វើការនៅការដ្ឋាន។

**សៈ** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែហើយ ហើយខ្ញុំអំមិញខ្ញុំសួរគាត់ថា ពាក្យស្លោកថា "មានទឹកមានត្រី" នេះគឺជាសុភាសិតដែលមានតាំងពីមុនរបបខ្មែរក្រហមនោះទៀត ឬក៏ជាលើកទី១ហើយដែលលោកហ្នឹងស្តាប់ឮពាក្យស្លោកហ្នឹងនៅលើការដ្ឋានទេ? <>

**ឆ៖** បាទ ពាក្យហ្នឹងខ្ញុំឮនៅហ្នឹងការដ្ឋាន ត្រង់ថាសុភាសិតហ្នឹងវាមានពីបរមកាលអីមក ព្រោះខ្ញុំនៅក្មេងដែរ ខ្ញុំអត់ដែលដឹងទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន ប៉ុន្តែសហភាតារបស់ខ្ញុំ លោក គង់ សំអុន នុំងគាត់មានសំណួរបន្តិចបន្តួចដើម្បីសួរ។ បើសិនជាលោកប្រធានអនុញ្ញាតពន្យារពេលឲ្យគាត់សួរបញ្ចប់គាត់នឹងឡើងសួរ លោកប្រធាន ឥឡូវហ្នឹងតែម្តង។

[១១:៣៦:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

Deleted: --

Deleted: លោកឮពាក្យហ្នឹងទាល់តែនៅការដ្ឋានហ្នឹងហើយ បានៗឮពាក្យហ្នឹង?

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជម្រាបសួរលោក ប៊ុច សុខា ។ ខ្ញុំមានសំណួរខ្លីទេ ហើយដំបូងខ្ញុំចង់ជម្រាបសួរលោកថា លោកបានបញ្ជាក់អំពីប្រវែងទំនប់១មករា មានរហូតដល់៥៨គីឡូ ហើយខ្ញុំចង់សួរលោកថា តើទំនប់នេះ លោករាប់ហ្នឹង ភ្ជាប់ទាំងទំនប់៦មករាផង បានន័យថា ទំនប់ពីរបញ្ចូលគ្នាមានប្រវែង៥៨គីឡូនេះ ឬមួយ យ៉ាងម៉េច? សូមលោកជួយបញ្ជាក់។

**លោក ប៊ុច សុខា៖**

**ឆ៖** បាទ លោកតុលាការ អាប្រវែងបណ្ដោយដែលខ្ញុំបានបញ្ជាក់នេះ ខ្ញុំចាំបានថា ប្រហែលវា មិនលើសពី៦០គីឡូទេ តែបើតិចជាង ក៏មិនទាបជាងអ្វីដែលជូនដំណឹងអំមិញដែរ។ ទំនប់ពីរហ្នឹង គឺភ្ជាប់ គ្នា មានចម្ងាយប៉ុណ្ណឹង បូកទាំងប្រឡាយទឹកផង ហើយមានចម្ងាយក្រោម៦០គីឡូហ្នឹង។

បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីទទឹងទំនប់បានទេ? ប្រវែងប៉ុន្មានម៉ែត្រ?

[១១:៣៧:៥២]

**ឆ៖** ខ្ញុំដូចជាមិនចាំទេ ព្រោះវាមិនៗមានស្មើគ្នាផង។

**ស៖** តើលោកបញ្ជាក់ថា អត់ស្មើគ្នាហ្នឹង បានន័យថា ទំនប់ហ្នឹងមានកន្លែងតូច កន្លែងធំ តើអ៊ីចឹ ងមែនទេ? ហើយលោកអាចបញ្ជាក់បានទេថា កន្លែងដែលធំប៉ុន្មាន ហើយកន្លែងដែលតូចប៉ុន្មាន?

**ឆ៖** ខ្ញុំដូចជាភ្លេចហើយ លោកតុលាការ។

**ស៖** បាទ សូមអរគុណ។ លោកអាចគណនាពីៗសាច់ដីដែលត្រូវយកទៅប្រើធ្វើជាទំនប់បានទេ គិតជាម៉ែត្រគូប?

**ឆ៖** អត់ទេ អត់បាន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចម្លើយ -- កំណត់ហេតុស្ដាប់ចម្លើយរបស់លោក ឯកសារ E3/403 បានន័យថា 403 ត្រង់ ERN ជាភាសាខ្មែរ 00389526, ភាសាបារាំង 00422243, ភាសាអង់គ្លេស 00403008។ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក នៅពេលដែលគេសួរអំពីទំនប់១មករា និងទំនប់៦មករា ខ្ញុំសូមដកស្រង់៖ "ការដាក់ឈ្មោះទំនប់៦មករានេះ គឺការកំណត់នៃថ្ងៃដែលយួនវាយ ចូលមកទឹកដីកម្ពុជាជាលើកដំបូង (នៅថ្ងៃទី០៦ មករា ឆ្នាំ១៩៧៨) ហើយក៏ជាថ្ងៃបើកការដ្ឋានទំនប់ ៦មករានេះដែរ" សូមចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា តើលោកដឹងពីថ្ងៃទី០៦ មករា ៧៨ ដែលជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថ្ងៃយួនវ៉ៃចូលនៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹងដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំដឹងតាមរយៈមេក្រុមខ្ញុំគាត់ប្រាប់ ថាគេដាក់ឈ្មោះហ្នឹងគឺអ៊ីចឹង តែត្រង់ឲ្យលម្អិតអីសម្រាប់ខ្លួនខ្ញុំដឹង ជាសម្រាប់ខ្លួនខ្ញុំដឹងផ្ទាល់ខ្លួន គឺមិនមានទេ ដឹងតាមពីប្រធានក្រុមខ្ញុំឈ្មោះ បងផាំ គាត់ប្រាប់អ៊ីចឹង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១១:៤០:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ ហើយសវនាការនៅថ្ងៃនេះបានចប់មុនពេលកំណត់ ហើយក៏មិនមានសាក្សីបម្រុងដែរ ហើយនៅរសៀលនេះ អង្គជំនុំជម្រះមិនធ្វើសវនាការទេ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៥ ខែមេសា*(ស៊ីក)* ឆ្នាំ២០១៥ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-851 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោក ប៊ិច សុខា ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្ដល់សក្ខីកម្មតាមរយៈសោតទស្សន៍រយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកពិតក្នុងរឿងក្ដីនេះ។ ការផ្ដល់សក្ខីកម្មរបស់លោកក៏បានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ សូមលោកមានសុខភាពល្អ ហើយទទួលបានសេចក្ដីសុខ សេចក្ដីចម្រើន លោក ប៊ិច សុខា។

**លោក ប៊ិច សុខា៖**

បាទ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បង្គាប់អនុរក្សមន្ទីរឃុំឃាំងខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វិញ នៅថ្ងៃចន្ទ ទី២៥ ខែឧសភា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាក៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៤២ នាទី)*